ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាឧទ្ធរណ៍

# តាងនាមប្រជារាស្ត្រខ្មែរ
## សាលាឧទ្ធរណ៍ ភ្នំពេញ

បង្កើតឡើងតាមច្បាប់ស្តីពីរៀបចំអង្គការតុលាការដែលប្រកាសប្រកាសឲ្យប្រើតាមព្រះរាជក្រមលេខ នស/រកម/០៧១៤/០១៥ ចុះថ្ងៃទី ១៦ ខែ កក្កដា ឆ្នាំ ២០១៤ ។

សំណុំរឿងព្រហ្មទណ្ឌ
លេខ: ៦៦៧
ចុះថ្ងៃទី ០៦.៦.១៨
សាលដីកា
លេខ : ៦៣ក្រ॥ "ញ"
ចុះថ្ងៃទី ១៩.៩.១៨

បានបើកសវនាការជាសាធារណៈនៅថ្ងៃទី ២៨ ខែ សីហា ឆ្នាំ ២០១៩ ដោយមានសមាសភាពចូលរួមដូចតទៅ :

សមាសភាពក្រុមប្រឹក្សាជំនុំជំរះ

១.ឯកឧត្តម [redacted] ជាប្រធាន
២.លោក [redacted] ជាចៅក្រុមប្រឹក្សា
៣.លោក [redacted] ជាចៅក្រមប្រឹក្សា

តំណាងមហាអយ្យការ
លោក [redacted]

ក្រឡាបញ្ជីសវនាការ
លោកស្រី [redacted]

*ដើម្បីជំនុំជំរះលើបណ្តឹងឧទ្ធរណ៍សំណុំរឿងព្រហ្មទណ្ឌចោទលេខ :៦៦៧ ចុះថ្ងៃទី ០៦ ខែ ៦ ឆ្នាំ ២០១៨ ដែលមាន :*

✓១.ជនជាប់ចោទឈ្មោះ [redacted] នាង([redacted] វណ្ណដា) ភេទប្រុស អាយុ ៥០ឆ្នាំ ជាតិខ្មែរ សាសនាព្រះពុទ្ធ មុខរបរ មៅការសំណង់ ទីកន្លែងកំណើតភូមិ អូរបេង ឃុំ អូរបេង ស្រុក បៃលិន ខេត្ត បាត់ដំបង មានទីលំនៅសព្វថ្ងៃជាប់ពន្ធនាគារខេត្ត បន្ទាយមានជ័យ ឪពុកឈ្មោះ [redacted] "ស" ម្តាយ ឈ្មោះ [redacted] "រ" ប្រពន្ធឈ្មោះ [redacted] មានកូន០២នាក់ ទោសពីមុនធ្លាប់ជាប់ពន្ធនាគារ២៥ឆ្នាំ ពីបទ: ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ។ (ក្នុងឃុំ)

-មានលោក [redacted] កក្តី ជាមេធាវីការពារ

✓២.ជនជាប់ចោទឈ្មោះ [redacted] មន្នី ហៅ ចៃនី ភេទស្រី អាយុ ៣២ឆ្នាំ ជាតិខ្មែរ សាសនាព្រះពុទ្ធ មុខរបរ នៅផ្ទះ ទីកន្លែងកំណើតភូមិ កោះរកាក្នុង ឃុំ កោះរកា ស្រុក កំពង់សៀម ខេត្ត កំពង់ចាម មានទីលំនៅសព្វថ្ងៃ [redacted] សិរីសោភ័ណ ខេត្ត បន្ទាយមានជ័យ ឪពុកឈ្មោះ [redacted] "រ" ម្តាយ ឈ្មោះ [redacted] "រ" ប្តីឈ្មោះ [redacted] វណ្ណដា ហៅ ដា ទោសពីមុនគ្មាន ។ (ក្នុងឃុំ)

-មានលោក [redacted] កក្តី ជាមេធាវីការពារ

៣.ជនជាប់ចោទឈ្មោះ [redacted] លីហៀង ហៅ ហៀង ភេទប្រុស អាយុ ៣៨ឆ្នាំ ជាតិខ្មែរ សាសនាព្រះពុទ្ធ ទីកន្លែងកំណើតភូមិ អូរចំលង់ ឃុំ តាសែន ស្រុក កំរៀង ខេត្ត បាត់ដំបង មាន




Scanned with CamScanner

ទីលំនៅសព្វថ្ងៃជាប់ពន្ធនាគារខេត្ត បន្ទាយមានជ័យ ឪពុកឈ្មោះ [redacted] "ស" ម្តាយឈ្មោ[redacted] មូត "រ" ប្រពន្ធឈ្មោះ [redacted] (លែងលះ) ទោសពីមុនធ្លាប់ជាប់ពន្ធនាគារ២៥ឆ្នាំ ពីបទ: ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ។ (ក្នុងឃុំ)

មានលោក [redacted] ឧត្តរ ជាមេធាវីការពារ

៤. ជនជាប់ចោទឈ្មោះ [redacted] សាវី ហៅ បាក់ ភេទប្រុស កើតឆ្នាំ ១៩៨០ ជាតិខ្មែរ សាសនាព្រះពុទ្ធ មុខរបរ កសិករ ទីកន្លែងកំណើតភូមិ សែនពន្លក ឃុំ សំរោង ស្រុក ទូមាស ខេត្ត កំពត មានទីលំនៅស[redacted]ខេត្ត បាត់ដំបង ឪពុកឈ្មោ[redacted] "ស" ម្តាយ ឈ្មោះ [redacted] "រ" ប្រពន្ធឈ្មោះ [redacted] (លែងលះ) ទោសពីមុនធ្លាប់ជាប់ពន្ធនាគារ២៥ឆ្នាំ ពីបទ: ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ។ (ក្នុងឃុំ)

-មានលោក [redacted] សុភា ជាមេធាវីការពារ

៥. ជនជាប់ចោទឈ្មោះ [redacted]ហេង ភេទប្រុស អាយុ ២៩ឆ្នាំ ជាតិខ្មែរ សាសនា ព្រះពុទ្ធ មុខរបរ កម្មករ ទីកន្លែងកំណើតភូមិ ក្របីរៀល ឃុំ ក្របីរៀល ស្រុក ពួក ខេត្ត សៀមរាប មានទីលំនៅសព្វថ្ងៃភូមិ [redacted] ថ្មពួក ខេត្ត បន្ទាយមានជ័យ ឪពុកឈ្មោះ [redacted] "ស" ម្តាយឈ្មោះ[redacted] "ស" ប្រពន្ធឈ្មោះ [redacted] (លែងលះ) ទោសពីមុនធ្លាប់ជាប់ពន្ធនាគារ ៦ឆ្នាំ ពីបទ: ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ។ (ក្នុងឃុំ)

-មានលោក [redacted]ភក្តី និង លោក [redacted] សុភា ជាមេធាវីការពារ

✓ ៦. ជនជាប់ចោទឈ្មោះ [redacted]សាវ៉ែន ហៅ ម៉ាប់ ហៅ ឡៀន ភេទប្រុស កើតឆ្នាំ ១៩៩២ ជាតិខ្មែរ សាសនាព្រះពុទ្ធ មុខរបរគ្មាន ទីកន្លែងកំណើតភូមិ គោកក្នុង ឃុំ កោះរកា ស្រុក កំពង់សៀម ខេត្ត កំពង់ចាម មានទីលំនៅសព្វថ្ងៃ[redacted] ខេត្ត បន្ទាយមានជ័យ ឪពុកឈ្មោះ [redacted] "រ" ម្តាយឈ្មោះ [redacted] "រ" នៅលីវ ទោសពីមុនគ្មាន ។ (ក្នុងឃុំ)

<u>ជាប់ចោទពីបទ</u> :ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន និង សំអាតប្រាក់ ប្រព្រឹត្តនៅចំណុចពន្ធនាគារខេត្ត បន្ទាយមានជ័យ និង ចំណុចបន្ទប់ជួលស្ថិតនៅភូមិ ទឹកថ្លា សង្កាត់ ទឹកថ្លា ក្រុង សិរីសោភ័ណ ខេត្ត បន្ទាយមានជ័យ កាលអំឡុងឆ្នាំ ២០១៦ ដល់ថ្ងៃទី ១៨ ខែ កញ្ញា ឆ្នាំ ២០១៦ ។

*បទល្មើសព្រហ្មទណ្ឌដែលមានចែងអោយផ្តន្ទាទោសតាមមាត្រា ៤០ កថាខណ្ឌ៣ និង កថាខណ្ឌ ៥ ចំណុច១ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន និង មាត្រា ៤០៤ និង មាត្រា ៤០៦ នៃក្រមព្រហ្មទណ្ឌ ។*

-មានលោក[redacted]ភក្តី ជាមេធាវីការពារ

៧. ជនជាប់ចោទឈ្មោះ [redacted]បីហា ហៅ គិត ភេទប្រុស កើតឆ្នាំ ១៩៨២ ជាតិខ្មែរ សាសនាព្រះពុទ្ធ ទីកន្លែងកំណើតភូមិ តាំងក្រង ឃុំ តាំងក្រង ស្រុក ប្រាសាទសំបូរ ខេត្ត កំពង់ធំ



Scanned with CamScanner

មានទីលំនៅសព្វថ្ងៃ[redacted]ស្រុក ប្រាសាទសំបូរ ខេត្ត កំពង់ធំ ឪពុកឈ្មោះ [redacted] ម្តាយ ឈ្មោះ[redacted] ទោសពីមុនធ្លាប់ជាប់ពន្ធនាគារ០៦ឆ្នាំ ។ (ក្នុងឃុំ)

<u>ជាប់ចោទពីបទ</u> :សមគំនិតក្នុងអំពើជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅចំណុចពន្ធនាគារខេត្ត បន្ទាយមានជ័យ និង ចំណុចបន្ទប់ជួលស្ថិតនៅភូមិ ទឹកថ្លា សង្កាត់ ទឹកថ្លា ក្រុង សិរីសោភណ័ ខេត្ត បន្ទាយមានជ័យ កាលអំឡុងឆ្នាំ ២០១៦ ដល់ថ្ងៃទី ១៨ ខែ កញ្ញា ឆ្នាំ ២០១៦ ។

*បទល្មើសព្រហ្មទណ្ឌដែលមានចែងអោយផ្តន្ទាទោសតាមមាត្រា ៤០ កថាខណ្ឌ៣ និង កថាខណ្ឌ ៥ ចំណុច១ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។*

-មានលោក[redacted]បុភា ជាមេធាវីការពារ

តាមសេចក្តីចម្លងនៃលិខិតបណ្តឹងឧទ្ធរណ៍លេខ :១៩ ចុះថ្ងៃទី ១៦ ខែ មីនា ឆ្នាំ ២០១៨ ឈ្មោះ ពេន នាង ប្តឹងឧទ្ធរណ៍នឹងសាលក្រមព្រហ្មទណ្ឌលេខ :០៧"ឆ" ចុះថ្ងៃទី ២៦ ខែ មករា ឆ្នាំ ២០១៨ របស់ខេត្ត បន្ទាយមានជ័យ គ្រង់ចំណុចសេចក្តីសម្រេចទាំងមូល ។

តាមសេចក្តីចម្លងនៃលិខិតបណ្តឹងឧទ្ធរណ៍លេខ :១២ ឈ្មោះ[redacted]សាវ៉ែន ,បណ្តឹងឧទ្ធរណ៍លេខ: ១១ ឈ្មោះ [redacted] សីហា ,តាមបណ្តឹងលេខ: ១០ ឈ្មោះ [redacted]លីហៀង , តាមបណ្តឹងលេខ: ០៩ ឈ្មោះ [redacted]ហេង ,តាមបណ្តឹងលេខ: ០៨ ឈ្មោះ[redacted]សារី និង តាមបណ្តឹងលេខ: ០៧ ឈ្មោះ[redacted]មន្នី (ចំណុច(ឃ) និង ចំណុចទី(២) ប្តឹងឧទ្ធរណ៍នឹងសាលក្រមព្រហ្មទណ្ឌលេខ :០៧"ឆ" ចុះថ្ងៃទី ៣០ ខែ មករា ឆ្នាំ ២០១៨ របស់សាលាដំបូងខេត្ត បន្ទាយមានជ័យ គ្រង់ចំណុចសេចក្តីសម្រេច ។

*ឯរឿងហេតុមានដូចតទៅ :*

កាលពីថ្ងៃទី ១៨ ខែ កញ្ញា ឆ្នាំ ២០១៦ វេលាម៉ោង ១៥ និង ៤៥នាទី ស្ថិតនៅចំណុចភូមិ ភ្នំកន្ទួត សង្កាត់ កំពង់ស្វាយ ក្រុង សិរីសោភ័ណ ខេត្ត បន្ទាយមានជ័យ ដោយអនុវត្តតាមវិធានញុះញង់ឲ្យលក់ដោយខុសច្បាប់នូវសារធាតុញៀន កម្លាំងការិយាល័យបទល្មើសគ្រឿងញៀន បានចុះធ្វើប្រតិបត្តិការបង្ក្រាបករណីជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ដោយធ្វើការឃាត់ខ្លួនជនសង្ស័យ០១នាក់ ឈ្មោះ[redacted] ចំរើន ហៅ ណុយ ភេទប្រុស អាយុ ១៧ឆ្នាំ តាមការស្តាប់ចម្លើយ និងសហការចង្អុលបង្ហាញពីជនសង្ស័យឈ្មោះ [redacted] ចំរើន ម៉ោង ១៨ និង ៣០នាទី នៅចំណុចភូមិ កកោះ ឃុំ អូរតាគី ស្រុក ថ្មគោល ខេត្ត បាត់ដំបង កម្លាំងយើងសហការជាមួយកម្លាំងអាវុធហត្ថ ខេត្ត បាត់ដំបង បានបន្តប្រតិបត្តិការឃាត់ខ្លួនជនសង្ស័យបានចំនួន១នាក់ទៀត ដែលមានឈ្មោះ [redacted] រ៉ូហ្សា ភេទស្រី អាយុ ២៨ឆ្នាំ ហើយឈ្មោះ [redacted] រ៉ូហ្សា បានសហការជាមួយកម្លាំងសមត្ថកិច្ចកងរាជអាវុធហត្ថ រួចបន្តការឃាត់ខ្លួនមេក្លោងធំដទៃទៀត ដែលជាទណ្ឌិតនៅក្នុងពន្ធនាគារខេត្ត បន្ទាយមានជ័យ ជាបន្តបន្ទាប់បានចំនួន០៧នាក់ទៀត ដែលមានឈ្មោះ[redacted]មន្នី ភេទស្រី អាយុ ៣២ឆ្នាំ ,ឈ្មោះ[redacted] សាវ៉ែន ភេទប្រុស អាយុ ២៨ឆ្នាំ ,ឈ្មោះ [redacted] នាង ភេទប្រុស អាយុ ៥០ឆ្នាំ , ឈ្មោះ [redacted]លីហៀង ភេទប្រុស អាយុ ៣៣ឆ្នាំ ,ឈ្មោះ [redacted] ហេង ភេទប្រុស អាយុ ២៩ឆ្នាំ ,ឈ្មោះ



Scanned with CamScanner

[redacted]សីហា ភេទប្រុស អាយុ ៣៥ឆ្នាំ និង ឈ្មោះ [redacted] សារី ភេទប្រុស អាយុ ៣៦ឆ្នាំ ។ បន្ទាប់មក នៅថ្ងៃទី ១៩ ខែ កញ្ញា ឆ្នាំ ២០១៦ សមត្ថកិច្ចបានចុះទៅទីតាំងអាគារជួល ដែលមាន១៨បន្ទប់ ស្ថិតនៅភូមិ ទឹកថ្លា សង្កាត់ ទឹកថ្លា ក្រុង សិរីសោភ័ណ ខេត្ត បន្ទាយមានជ័យ ជាកម្មសិទ្ធិរបស់ឈ្មោះ [redacted] នាង ហៅ [redacted] វណ្ណដា និង ប្រពន្ធឈ្មោះ [redacted] មន្នី បានធ្វើការឆែកឆេរបន្ទប់ស្នាក់នៅរបស់ឈ្មោះ [redacted] មន្នី និង ឆែកឆេរបន្ទប់ស្នាក់នៅរបស់ឈ្មោះ [redacted] ណារ៉ែន ភេទស្រី អាយុ ២៨ឆ្នាំ រឹបអូសបានវត្ថុតាងមួយចំនួនធំ ហើយសមត្ថកិច្ចបានសម្រេចបិទទីតាំងអាគារជួលទាំងមូលតែម្តង ។ អាគារជួល និង វត្ថុតាងដែលចាប់យកទាំងអស់ គឺបានមកពីអំពើល្មើសក្នុងបទល្មើសគ្រឿងញៀនដើម្បីសម្អាតប្រាក់ ។

បានឃើញសាលក្រមព្រហ្មទណ្ឌលេខ :០៧"ឆ" ចុះថ្ងៃទី ២៦ ខែ មករា ឆ្នាំ ២០១៨ របស់សាលាដំបូងខេត្ត បន្ទាយមានជ័យ មានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ:

ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] មុន្នី ,ឈ្មោះ [redacted] សារ៉ែន ,ឈ្មោះ [redacted] សារី , ឈ្មោះ [redacted] ហេង ,ឈ្មោះ [redacted] លីហៀង ,ឈ្មោះ [redacted] រ៉ូហ្សា ឈ្មោះ [redacted] ចំរើន និង ឈ្មោះ [redacted] សីហា កំបាំងមុខឈ្មោះ [redacted] នាង ឈ្មោះ [redacted] ណារ៉ែន

១- ផ្តន្ទាទោសលើជនជាប់ចោទដូចខាងក្រោម៖

ក-ឈ្មោះ [redacted] ចំរើន ភេទប្រុស អាយុ ១៧ឆ្នាំ (អត្តសញ្ញាណខាងលើ) ដាក់ពន្ធនាគារកំណត់ចំនួន០៧ឆ្នាំ៦ខែ ពីបទ: ជួញដូរ និង ប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅភូមិ ទឹកថ្លា សង្កាត់ ទឹកថ្លា ក្រុង សិរីសោភ័ណ ខេត្ត បន្ទាយមានជ័យ កាលពីអំឡុងឆ្នាំ ២០១៦ ដល់ថ្ងៃទី ១៨ ខែ កញ្ញា ឆ្នាំ ២០១៦ បទល្មើសមានចែង និង ផ្តន្ទាទោសតាមមាត្រា ៤០ កថាខណ្ឌ៣ និង កថាខណ្ឌ ៥ ចំណុច១ និង មាត្រា ៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន និង មាត្រា ១៦០ នៃក្រមព្រហ្មទណ្ឌ។

ខ-ឈ្មោះ [redacted] រ៉ូហ្សា ហៅ ស៊ីណា ហៅ មុំ ភេទស្រី អាយុ ២៨ឆ្នាំ (អត្តសញ្ញាណខាងលើ) ដាក់ពន្ធនាគារកំណត់ចំនួន០១ឆ្នាំ ៦ខែ ពីបទ: ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្ត នៅភូមិ ទឹកថ្លា សង្កាត់ ទឹកថ្លា ក្រុង សិរីសោភ័ណ ខេត្ត បន្ទាយមានជ័យ កាលពីអំឡុងឆ្នាំ ២០១៦ ដល់ថ្ងៃទី ១៨ ខែ កញ្ញា ឆ្នាំ ២០១៦ បទល្មើសមានចែង និង ផ្តន្ទាទោសតាមមាត្រា៤០ កថាខណ្ឌ៣ កថាខណ្ឌ ៨ និង មាត្រា ៣២ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

គ-ឈ្មោះ [redacted] នាង (ឈ្មួន វណ្ណដា) ភេទប្រុស កើតឆ្នាំ ១៩៨០ (អត្តសញ្ញាណខាងលើ)ដាក់ពន្ធនាគារកំណត់០៨ឆ្នាំ ពីបទ: ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន និង សម្អាតប្រាក់ ប្រព្រឹត្តនៅចំណុចពន្ធនាគារខេត្ត បន្ទាយមានជ័យ និង ចំណុចបន្ទប់ជួលស្ថិតនៅភូមិ ទឹកថ្លា សង្កាត់ ទឹកថ្លា ក្រុង សិរីសោភ័ណ ខេត្ត បន្ទាយមានជ័យ កាលពីអំឡុងឆ្នាំ ២០១៦ ដល់ថ្ងៃទី ១៨ ខែ កញ្ញា ឆ្នាំ ២០១៦ បទល្មើសមានចែង និង ផ្តន្ទាទោសតាមមាត្រា៤០ កថាខណ្ឌ៣ និង កថាខណ្ឌ



Scanned with CamScanner

៥ ចំណុច១ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន និង មាត្រា ៤០៤ និង មាត្រា ៤០៦ នៃក្រមព្រហ្មទណ្ឌ ។

យ.ឈ្មោះ [redacted] មន្នី ហៅ ថៃនី ភេទស្រី អាយុ ៣២ឆ្នាំ (អត្តសញ្ញាណខាងលើ)

ង.ឈ្មោះ [redacted] លីហៀង ហៅ ហៀង ភេទប្រុស អាយុ ៣៤ឆ្នាំ (អត្តសញ្ញាណខាងលើ)

ច.ឈ្មោះ [redacted] សារី ហៅ បាក់ ភេទប្រុស កើតឆ្នាំ ១៩៨០ (អត្តសញ្ញាណខាងលើ)

ឆ.ឈ្មោះ [redacted] ហេង ភេទប្រុស អាយុ ២៩ឆ្នាំ (អត្តសញ្ញាណខាងលើ)

ជ.ឈ្មោះ [redacted] សារ៉ែន ហៅ ម៉ាប់ ហៅ ឡែន ភេទប្រុស កើតឆ្នាំ ១៩៩២ (អត្តសញ្ញាណខាងលើ)

ឈ.ឈ្មោះ [redacted] ពការ៉ែន ភេទស្រី កើតឆ្នាំ ១៩៨៩ (អត្តសញ្ញាណខាងលើ)

ដាក់ពន្ធនាគារក្នុងម្នាក់ ៗ កំណត់០៥ឆ្នាំ ពីបទ: ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន និង សម្អាតប្រាក់ ប្រព្រឹត្តនៅចំណុចពន្ធនាគារខេត្ត បន្ទាយមានជ័យ និង ចំណុចបន្ទប់ជួល ស្ថិតនៅភូមិ ទឹកថ្លា សង្កាត់ ទឹកថ្លា ក្រុង សិរីសោភ័ណ ខេត្ត បន្ទាយមានជ័យ កាលពីអំឡុងឆ្នាំ ២០១៦ ដល់ថ្ងៃទី ១៨ ខែ កញ្ញា ឆ្នាំ ២០១៦ បទល្មើសមានថែង និង ផ្តន្ទាទោសតាមមាត្រា ៤០ កថាខណ្ឌ៣ កថាខណ្ឌ៥ ចំណុច១ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន និង មាត្រា ៤០៤, មាត្រា ៤០៦ នៃក្រមព្រហ្មទណ្ឌ។

ញ.ឈ្មោះ [redacted] សីហា ហៅ គិត ភេទប្រុស កើតឆ្នាំ ១៩៨២ (អត្តសញ្ញាណខាងលើ)

ដាក់ពន្ធនាគារកំណត់០៥ឆ្នាំ ពីបទ: សមគំនិតក្នុងអំពើជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅចំណុចពន្ធនាគារខេត្ត បន្ទាយមានជ័យ និង ចំណុចបន្ទប់ជួល ស្ថិតនៅភូមិ ទឹកថ្លា សង្កាត់ ទឹកថ្លា ក្រុង សិរីសោភ័ណ ខេត្ត បន្ទាយមានជ័យ កាលពីអំឡុងឆ្នាំ ២០១៦ ដល់ថ្ងៃទី ១៨ ខែ កញ្ញា ឆ្នាំ ២០១៦ បទល្មើសមានថែង និង ផ្តន្ទាទោសតាមមាត្រា ៤០ កថាខណ្ឌ៣ កថាខណ្ឌ៥ ចំណុច១ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន និង មាត្រា ២៩ នៃក្រមព្រហ្មទណ្ឌ។

២- រឹបអូសទ្រព្យសម្បត្តិដី និង ផ្ទះ ជាអាគារបន្ទប់ជួលរបស់ឈ្មោះ [redacted] នាង និង ឈ្មោះ [redacted] មន្នី ស្ថិតនៅភូមិ ទឹកថ្លា សង្កាត់ ទឹកថ្លា ក្រុង សិរីសោភ័ណ ខេត្ត បន្ទាយមានជ័យ ដែលបានបង្កកតាមដីកាបង្កកទ្រព្យសម្បត្តិលេខ: ១៩០៣ ពស.ព្រទ ចុះថ្ងៃទី ២២ ខែ មីនា ឆ្នាំ ២០១៧ របស់ចៅក្រមស៊ើបសួរសាលាដំបូងខេត្ត បន្ទាយមានជ័យ ។

៣. រឹបអូសនូវវត្ថុតាងជាថ្នាំញៀន ដូចក្នុងកំណត់ហេតុដែលដកហូតបានពីឈ្មោះ [redacted] ចំរើន និង ឈ្មោះ [redacted] វ៉ូហ្វា ។

៤. រឹបអូសនូវសម្ភារៈមាន ជញ្ជីងថ្លឹងគ្រឿងញៀន ,រថយន្តម៉ាកតូយ៉ូតាកូរ៉ូឡាឆ្នាំ ១៩៩៤ ពណ៌បៃតងចាស់ ទូរស័ព្ទដៃ,ម៉ាស៊ីន MP4 កូនថង់សម្រាប់ច្រកគ្រឿងញៀន និង សម្ភារៈសម្រាប់



Scanned with CamScanner

ផក់គ្រឿងញៀន ដូចមានក្នុងកំណត់ហេតុដែលសមត្ថកិច្ចដកហូតបានពីឈ្មោះ [redacted] មន្នី ឈ្មោះ [redacted] សាវ៉ែន ឈ្មោះ [redacted] សីហា ,ឈ្មោះ [redacted] នាង និង ឈ្មោះ [redacted] លីហៀង ។

៥. បញ្ឈប់អានុភាពដីកាបង្គាប់ឲ្យចាប់ខ្លួនលេខ: ២៨៨ ចុះថ្ងៃទី ០៨ ខែ តុលា ឆ្នាំ ២០១៦ លើឈ្មោះ [redacted] ណាវ៉ែន របស់ចៅក្រមស៊ើបសួរសាលាដំបូងខេត្ត បន្ទាយមានជ័យ ។

៦. បង្គាប់ឲ្យចាប់ខ្លួនឈ្មោះ [redacted] ណាវ៉ែន ភេទស្រី កើតឆ្នាំ ១៩៨៩ (អត្តសញ្ញាណខាងលើ) តាមមាត្រា ៣៥៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

សាលក្រមនេះជំនុំជំរះនៅថ្ងៃទី ១៩ ខែ តុលា ឆ្នាំ ២០១៧ និង ប្រកាសជាសាធារណៈ នៅថ្ងៃទី ២៦ ខែ មករា ឆ្នាំ ២០១៨ នៅសាលាដំបូងខេត្ត បន្ទាយមានជ័យ ។ ទុកសិទ្ធិឲ្យប្តឹងទាស់ និង ប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់ ។

បានឃើញរបាយការណ៍រឿងចុះថ្ងៃទី ២៦ ខែ ១២ ឆ្នាំ ២០១៨ របស់សាលាឧទ្ធរណ៍។

បានឃើញសេចក្តីសន្និដ្ឋានចុះថ្ងៃទី ១៨ ខែ មករា ឆ្នាំ ២០១៩ របស់មហាអយ្យការអមសាលាឧទ្ធរណ៍ ។

បានឃើញដីកាចាត់តាំងសមាសភាពក្រុមប្រឹក្សាជំនុំជំរះលេខ: ១១៧ដក ឧ១៨ ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ២០១៨ របស់សាលាឧទ្ធរណ៍ ។

## នាពេលសវនាការ

ឈ្មោះ [redacted] សីហា ជាជនជាប់ចោទ (អវត្តមាន)

ឈ្មោះ [redacted] មន្នី ជាជនជាប់ចោទ (អវត្តមាន)

ប្រធានក្រុមប្រឹក្សាអានរបាយការណ៍

ឈ្មោះ [redacted] នាង ឆ្លើយថា ខ្លួនមិនសុខចិត្តប្តឹងឧទ្ធរណ៍មកនេះ ដោយសារពេលគេចាប់ខ្លួនមកនេះ ខ្លួនពិតជាបានប្រព្រឹត្តមែន តែទោសដាក់ធ្ងន់ពេក ដោយគ្រឿងញៀននោះតិចតួច ។ នៅតុលាការប្រទេសថៃផ្តន្ទាទោសខ្លួន ២៥ឆ្នាំ ខ្លួនអនុវត្តទោសនៅថៃបាន៦ឆ្នាំគេបានបញ្ជូនខ្លួនមកកម្ពុជាថ្ងៃទី ២៨ ខែ ៣ ឆ្នាំ ២០១៤ ហើយខ្លួនជាប់នៅបន្ទាយមានជ័យរហូតមក ។ គេបានឲ្យខ្លួនចេញមកធ្វើសិប្បកម្មនៅខាងក្រៅពេលឈ្មោះ [redacted] រ៉ូហ្សា បានចេញទៅផ្ទះរួចមកលេង ហើយបានទំនាក់ទំនងរកថ្នាំពីខ្លួនក៏រកឲ្យទៅ រួចគេឆ្លើយដាក់ខ្លួនតែម្តង ។ ដំបូងមកលេងធម្មតា បន្ទាប់មកមានទំនាក់ទំនងរកថ្នាំតាមទូរស័ព្ទ ។ កាលដែលខ្លួនមានគំនិតបើកសិប្បកម្មក្នុងពន្ធនាគារនេះ ដើម្បីបានប្រាក់កម្រៃ និង ចែកតម្រេះខ្លះឲ្យអ្នកធ្វើជាមួយ ។ ខ្លួនត្រូវបានលើកលែងបន្ធូរបន្ថយទោសច្រើនដងដែរ ខ្លួនប្រហែលជិតរួចហើយទោសមុន នៅទោសក្រោយនេះ។ ក្រោយពីទំនាក់ទំនងជាមួយឈ្មោះ [redacted] រ៉ូហ្សា ហើយមានការអាណិតដោយនាងមានកូន ហើយចេះតែទូរស័ព្ទមករកខ្លួនឲ្យ រកកម្រៃខ្លះដើម្បីចិញ្ចឹមកូន ។ ការលក់នេះទំនាក់ទំនងជាមួយជនជាតិថៃឈ្មោះ យៃ៍ សរុបទៅខ្លួនទំនាក់ទំនងជាមួយឈ្មោះ រ៉ូហ្សា មិនលើសពីបីដងទេ ម្តងប្រហែលជាមួយជ្រុង ,មួយជ្រុង ៤៥០ ធ្លាប់ឲ្យឈ្មោះ [redacted] សាវ៉ែន យកទៅឲ្យឈ្មោះ រ៉ូហ្សា ,ឈ្មោះ ផល ធ្លាប់ស្គាល់គ្នា [redacted] សាវ៉ែម



Scanned with CamScanner

ត្រូវជាប្អូនថ្លៃ មុនមានរឿងនេះប្រហែលមួយខែ ឆ្នាំ ២០១៦ ,សមត្ថកិច្ចចូលឆែកឆេរនៅថ្ងៃទី ១៨-៥-២០១៦ ,ការវេរលុយ វេរតាមវីង ភាគច្រើន [redacted] រ៉ូហ្សា ជូនកាលវេរឲ្យ ជូនកាលយកមកឲ្យដល់រោងសិប្បកម្ម ,ផ្ទះនេះធ្វើមិនទាន់ហើយជាស្ថាពរទេ ,ខ្លួនលក់ផ្ទះខ្លួននៅកំរៀងយកមកធ្វើ មានប្អូន និង ម្តាយ ហើយផ្ទះនៅកំរៀងឈ្មោះម្តាយ ,ផ្ទះនៅកំរៀងលក់បានជាងបួនលានបាត , ផ្ទះដែលតុលាការរឹបអូសឈ្មោះ [redacted] មុនី ,ទិញដីមុនមានរឿងមួយឆ្នាំ គឺឆ្នាំ ២០១៥ ទិញរួចមិនដល់មួយខែបានធ្វើផ្ទះ ,ផ្ទះធ្វើរួចប្រហែលជាពីរខែទៀតបន្ទាប់ពីមានរឿង ,ពេលឈ្មោះ [redacted] រ៉ូហ្សា វេរប្រាក់មកជូនឲ្យ [redacted] វ៉ុន [redacted] រ៉ា ទៅទទួល ,ខ្លួនរកស៊ីជាមួយ [redacted] រ៉ូហ្សា មិនលើសពីបីដងទេ ,ប្អូនស្រីខ្លួនជាអ្នកទុកលុយឲ្យខ្លួន វាឈ្មោះ [redacted] ចាន់ដា ។ មុនមានរឿងនេះខ្លួន និង ឈ្មោះ [redacted] រ៉ូហ្សា រកាំរកូសគ្នា នៅពេលគេចាប់ឈ្មោះ [redacted] រ៉ូហ្សា ។ មានទំនាក់ទំនងជាមួយអ្នកផ្សេងហើយ ។ ឆ្លើយដាក់ខ្លួន ។ អ្នកនៅបន្ទប់ជាមួយគ្នាមានឈ្មោះ [redacted] លីហៀង ឈ្មោះ [redacted] សីហា ឈ្មោះ [redacted] សារី ឈ្មោះ [redacted] ហេង អ្នកទាំងអស់នេះមិនដឹងរឿងខ្លួនទាំងអស់ មានតែឈ្មោះ [redacted] សារ៉ែម មួយទេ ដែលខ្លួនប្រើក្នុងរឿងទាក់ទងទៅនឹងគ្រឿងញៀន ប្រពន្ធខ្លួនក៏ដូចគ្នា គាត់អត់បានដឹងអ្វី ទាំងអស់មកជាប់ប្រាំបីដែរ ហានទាំងកូនតូចខ្លួន ឯការឆែកឆេរបន្ទប់ឃើញគ្រឿងញៀនក៏ពុំមែនជាការពិតទេ ព្រោះថា កញ្ចប់ថ្នាំដែលរកឃើញនោះ ជាកញ្ចប់ថ្នាំឈឺចង្កេះ។ សំណូមពរ ដោយខ្លួននៅជាប់ពន្ធនាគារច្រើនឆ្នាំ ខ្លួនទទួលកំហុស សុំតុលាការបន្ធូរបន្ថយទោស សុំឲ្យបាននៅតិចបំផុត ។

ឈ្មោះ [redacted] សារ៉ែន ឆ្លើយថា ប្តឹងឧទ្ធរណ៍មកនេះ ខ្លួនមិនសុខចិត្តនឹងការកាត់ទោសខ្លួនដែលខ្លួនបានយកទៅឲ្យគេបានតែពីរដង ។ ខ្លួនមិនចេះប្រើ និង មិនរកទេ គ្រឿងញៀន គឺ [redacted] នាង ជាអ្នកប្រើខ្លួនឲ្យទៅយកពីម្នាក់ថៃពីប៉ោយប៉ែតឲ្យឈ្មោះ [redacted] រ៉ូហ្សា នៅក្នុងទីរួមខេត្តបន្ទាយមានជ័យ ,ខ្លួនកាន់គ្រឿងញៀននេះតម្លៃប្រហែលជាចិតសិបម៉ឺនរៀល , ឈ្មោះ [redacted] រ៉ូហ្សា ឲ្យលុយនៅពេលដែលខ្លួនយកឥវ៉ាន់ឲ្យ [redacted] រ៉ូហ្សា នៅពេលឈ្មោះ [redacted] នាង គាត់ប្រើ គឺតែពីរដងគត់ ឯប្រាក់ឈ្មោះ [redacted] នាង និង ឈ្មោះ [redacted] ហ្សា ខ្លួនអត់ដឹងផង គាត់ឲ្យថាយត្រឹម បួនប្រាំម៉ឺន ។ ឈ្មោះ [redacted] សារ៉ែន ឆ្លើយថា ខ្លួន និង ឈ្មោះ [redacted] វន្នី ចូលឆែកបន្ទប់ ចូលរួមជាមួយនឹងសមត្ថកិច្ច ,ពេលចូលឆែកនោះ ម្ចាស់បន្ទប់មិននៅទេ មិនចាំរឿងពេលចូលរួមឆែកបន្ទប់ ថា បានផ្តិតមេដៃឬអត់ទេ ។ សំណូមពរបន្ធូរបន្ថយទោសឆាប់បានចេញទៅផ្ទះ ។

ឈ្មោះ [redacted] លីហៀង ឆ្លើយថា ខ្លួនធ្លាប់ជាប់ពន្ធនាគារនៅថៃ ខ្លួនប្តឹងឧទ្ធរណ៍មកនេះ ដោយមូលហេតុ ខ្លួនអត់ដឹង អ្វីទាំងអស់ ,ពេលផ្ទេរពីថៃមកឲ្យខ្លួននៅបន្ទប់មួយ ដល់ពេលគេបញ្ចូលបន្ទប់ទៅតាមទោស ដោយបន្ទប់ខ្លួនសុទ្ធតែគ្រឿងញៀនទាំងអស់ ឯឈ្មោះ [redacted] សារី វេរលុយឲ្យឈ្មោះ [redacted] ណារ៉ែន ជាលុយទិញម្ហូប ,ខ្លួនមិនបានដឹងរឿងទេ ក្រៅពីការខាត់តុ-ទូ ពេលចេញទៅខាងក្រៅ ។ ពេលសមត្ថកិច្ចឆែកឆេរ មានតែឈ្មោះ [redacted] សារ៉ែន ទេដែលចូលឆែកបន្ទប់ ។ ខ្លួនជាប់ពន្ធនាគារនៅថៃ៨ឆ្នាំជាង បានស្គាល់ [redacted] ណារ៉ែន ដោយសារពួកម៉ាក ខ្លួននាំស្គាល់តាមទូរ



Scanned with CamScanner

ស័ព្ទ ។ ក្រោយទាក់ទងបានមួយរយៈមក ស្គាល់ឈ្មោះ [redacted] នាង បានណែនាំឲ្យចូល ផ្ទះឈ្មោះ [redacted] មុនី ជាប្រពន្ធ [redacted] នាង ។ សំណូមពរសុំរួចផុតពីការចោទ ព្រោះខ្លួនមិនបានធ្វើ ។

ឈ្មោះ [redacted] ហេង ឆ្លើយថា ខ្លួនជាអ្នកដាំបាយធ្វើម្ហូប មិនបានដឹងរឿងអ្វីទាំងអស់ក្នុងរឿងនេះ។ ពីដើមមកក៏ខ្លួនជាអ្នកដាំបាយធ្វើម្ហូបឲ្យអ្នកទោសដែរ ពេលគាត់ដឹងខ្លួនចេះធ្វើម្ហូប [redacted] នាង ពាត់បានសុំខ្លួនទៅរោងសិប្បកម្មជួយធ្វើម្ហូបឲ្យគាត់ ។ ខ្លួនហ៊ានស្បថចំពោះវត្ថុស័ក្តិសិទ្ធិកាច់កខ្លួន កាលបើខ្លួនដឹងរឿងនេះ ។ រឿងមុនជាប់៦ឆ្នាំ ជិតរួចហើយ បែរជាមកជាប់រឿងនេះដោយមិនបានដឹងអ្វីទាល់តែសោះ ។ ចម្លើយរបស់ខ្លួននៅពេលមុនក៏បានឆ្លើយអញ្ចឹង ខ្លួនរក្សាចម្លើយដដែល។ សំណូមពរតុលាការរកយុត្តិធម៌ឲ្យខ្លួនផង ។

ឈ្មោះ [redacted] សាវី ឆ្លើយថា ខ្លួនមកមុនគាត់ ជាប់ទោស២៥ឆ្នាំដូចគ្នា តែខុសគ្នា ដោយមុនដំបូងនៅបន្ទប់មួយទេ តែនៅពេលតម្រូវឲ្យដាក់អ្នកទោសធ្ងន់បន្ទប់មួយផ្សេង ទើបខ្លួនត្រូវគេឲ្យដូរបន្ទប់តាមទោស ២៥ឆ្នាំ ។ ឈ្មោះ [redacted] រ៉ូហ្សា ធ្លាប់ឃើញកាលនៅពន្ធនាគារ ដល់ពេលចេញទៅខ្លួនមិនដែលឃើញទេ ។ មានគេនៅថៃរាប់អានគ្នា អាណិតផ្ញើលុយឲ្យខ្លួនចាយ, ផ្ញើម្តងមួយម៉ឺនបាតប្រហែលពីរបីខែម្តង ផ្ញើតាមរយៈបងប្អូននៅខ្មែរ ហើយខ្លួនពឹងឲ្យបងប្អូនជួយបើកឲ្យ។ ឈ្មោះ [redacted] ណារ៉ែន បើកឲ្យដោយគាត់ជាសង្សាររបស់ឈ្មោះ [redacted] លីហៀង អញ្ចឹងពឹងគាត់ឲ្យបើកឲ្យទៅ ទណ្ឌកម្មខ្លួនបានអនុវត្តរួចអស់ហើយ សព្វថ្ងៃនេះជាប់តែរឿងនេះ ថ្ងៃទី ២៣-២៤ ខែ ៩ ឆ្នាំ នេះទើបខ្លួនជាប់គ្រប់បីឆ្នាំ ។ សំណូមពរតុពកការរកយុត្តិធម៌ឲ្យខ្លួនផង ខ្លួនមិនបានធ្វើអ្វីខុស ។

តំណាងមហាអយ្យការសន្និដ្ឋានថា ក្នុងសំណុំរឿងនេះបើពិនិត្យទៅលើអង្គហេតុមានការប្រមូកប្រមល់ដែលមានមនុស្សដល់ទៅដប់នាក់ពាក់ព័ន្ធសំខាន់ក្នុងរឿងមានតែឈ្មោះ [redacted] នាង បន្ទាប់ឈ្មោះ [redacted] សារ៉ែន ចំណែកអ្នកដទៃទៀតហាក់បីមិនពាក់ព័ន្ធទាល់តែសោះ ក្នុងនោះខ្លះជាចុងភៅមិនដឹងអីទាល់តែសោះជាប់ប្រាំឆ្នាំដែរ អ្នកពាក់ព័ន្ធដែលត្រូវនោះមានឈ្មោះសាន សារ៉ែន និង ឈ្មោះ [redacted] នាង ,ចំពោះការរឹបអូសវិញក៏មានលក្ខណៈមិនច្បាស់លាស់ មិនរកឲ្យឃើញថាទ្រព្យនោះមានមុនការរកស៊ីគ្រឿងញៀន ឬ បានក្រោយរកស៊ីគ្រឿងញៀន ចាំខ្ញុំធ្វើសេចក្តីសន្និដ្ឋានខ្លះ ៗ ដើម្បីដាក់ជូនតាមក្រោយ ខ្លួនសុំទមូចក្រុមប្រឹក្សាបែងចែកអង្គហេតុឲ្យបានសុក្រឹត្យ រកយុត្តិធម៌ឲ្យជនជាប់ចោទ អ្នកប្រព្រឹត្តត្រូវតែជាប់ទោស អ្នកមិនប្រព្រឹត្តត្រូវតែរួចខ្លួន ដូចជាឈ្មោះ [redacted] ហេង ឯអ្នកដទៃទៀតសុំពិចារណាលើទណ្ឌកម្ម គួរតែបន្ធូរបន្ថយ ហើយឈ្មោះ [redacted] លីហៀង ក៏គួរតែរួចផុតពីបទចោទផងដែរ សូមបញ្ជាក់ថា ទ្រព្យសម្បត្តិនេះមិនជាប់នឹងការលាងលុយទេ បើពិនិត្យទៅលើអង្គហេតុនេះ ។

លោក [redacted] ឧត្តម មេធាវីការពារឲ្យជនជាប់ចោទឈ្មោះ [redacted] លីហៀង ធ្វើសេចក្តីសន្និដ្ឋានការពារដូចតទៅ: តាមការសួរដេញដោលចំពោះមុខបញ្ជាក់បានថាកូនក្តីខ្លួន មិនបានប្រព្រឹត្តដូចការចោទប្រកាន់ទេ គ្រាន់តែជាអ្នករស់នៅបន្ទប់ជាមួយឈ្មោះ [redacted] នាង ដូចមានការបញ្ជាក់ពីជនផ្សេងទៀតក៏ថា កូនក្តីខ្លួនមិនពាក់ព័ន្ធនឹងគ្រឿងញៀននេះទេ មានតែការរស់នៅតែ



Scanned with CamScanner

មួយគត់ដែល ត្រូវកូនក្តីខ្លួនបានគេចោទប្រកាន់មកនេះតែម្តង សំណូមពរអនុញ្ញាតឲ្យកូនក្តីខ្លួន រួចផុតពីបទចោទ ។

លោក [redacted] ភក្តី មេធាវីការពារឲ្យជនជាប់ចោទឈ្មោះ [redacted] នាង ឈ្មោះ [redacted] សារ៉ែន ឈ្មោះ [redacted] មន្នី ធ្វើសេចក្តីសន្និដ្ឋានការពារដូចតទៅ: ខ្លួនគាំទ្រទៅលើសេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ តាមអង្គហេតុនៃរឿងនេះគឺកើតឡើងពោមវិធានញុះញង់ដែលចេញពីឈ្មោះ [redacted] ចំរើន ហើយបន្តជាហូរហែនូវហេតុទាំងនេះ ដែលកើតជាមួយនឹងឈ្មោះ [redacted] រ៉ូហ្សា ម្នាក់គត់ ហើយកូនក្តីខ្លួន ឈ្មោះ [redacted] នាង ក៏បានទទួលស្គាល់ផងដែរថា ដោយសារតែគាត់ម្នាក់គត់ធ្វើឲ្យអ្នកដទៃជាប់ដោយសារគាត់ជាមួយឈ្មោះ [redacted] រ៉ូហ្សា ដូចនេះសូមក្រុមប្រឹក្សាពិចារណាតាមមាត្រា ៩៣ នៃក្រម សូមផ្តល់ស្ថានសម្រាលឲ្យគាត់ ពីព្រោះកូនក្តីខ្លួន [redacted] នាង ដែលបានទទួលស្គាល់កំហុស និង មានការសោកស្តាយយ៉ាងខ្លាំង និង ចំណុចរឹបអូសទ្រព្យសម្បត្តិសុំពិចារណាផងដែរ , ចំពោះឈ្មោះ [redacted] សីហា និង ឈ្មោះ [redacted] សារី វិញ គឺគាត់បានបញ្ជាក់ហើយថា មិនបានដឹងរឿង ឬសកម្មភាពជួញដូរគ្រឿងញៀន គាត់គ្រាន់តែរួមបន្ទប់តែមួយជាមួយឈ្មោះ [redacted] នាង គាត់មានពាក់ព័ន្ធតែបន្តិចរឿងវេរលុយ គាត់បញ្ជាក់រួចហើយគឺវេរលុយទិញម្ហូប សំណូមពរសុំឲ្យកូនក្តីខ្លួនរួចពីបទចោទប្រកាន់ ។

លោក [redacted] សុភា មេធាវីការពារឲ្យជនជាប់ចោទឈ្មោះ [redacted] សារី និង ឈ្មោះ [redacted] សីហា ធ្វើសេចក្តីសន្និដ្ឋានការពារដូចតទៅ: តុលាការបានចោទប្រកាន់លើកូនក្តីខ្ញុំឈ្មោះ [redacted] សារី ពីបទ: ជួញដូរដោយខុសច្បាប់ ប្រព្រឹត្តនៅពន្ធនាគារខេត្ត បន្ទាយមានជ័យ កាលពីថ្ងៃទី ១៨ ខែ កញ្ញា ឆ្នាំ ២០១៦ និង ឈ្មោះ [redacted] សីហា ពីបទ: សមគំនិតក្នុងអំពើជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅចំណុចពន្ធនាគារខេត្ត បន្ទាយមានជ័យ ដូចគ្នា គឺកូនក្តីខ្ញុំ តាំងពីសាលាដំបូងរហូតមក បានឆ្លើយបញ្ជាក់ឆ្លើយថា គាត់មិនបានប្រព្រឹត្តដូចការចោទប្រកាន់នេះទេ ពួកគាត់ទើបតែមកនៅបន្ទប់ជាមួយឈ្មោះ [redacted] នាង ពីរ-បីខែប៉ុណ្ណោះ ចំពោះការវេរលុយគឺប្រពន្ធគាត់វេរមកឲ្យទិញម្ហូប មិនពាក់ព័ន្ធនឹងថ្នាំញៀនទេ សូមឯកភាពទៅនឹងសេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ សំណូមពរក្រុមប្រឹក្សាសម្រេចឲ្យកូនក្តីខ្ញុំបានរួចផុតពីបទចោទប្រកាន់ ។

ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទឆ្លើយ និង ស្នើសុំ

ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារឲ្យជនជាប់ចោទឆ្លើយសុំ

ក្រោយពីបានពិនិត្យឯកសារដែលពាក់ព័ន្ធល្អិតល្អន់

ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

## សាលាឧទ្ធរណ៍



Scanned with CamScanner

## យល់ឃើញថា

១- បណ្ដឹងឧទ្ធរណ៍ចុះថ្ងៃទី ១៦ ខែ ៣ ឆ្នាំ ២០១៨ របស់ជនជាប់ចោទឈ្មោះ [redacted] នាង និង បណ្ដឹងឧទ្ធរណ៍ចុះថ្ងៃទី ៣០ ខែ ០១ ឆ្នាំ ២០១៨ របស់ជនជាប់ចោទឈ្មោះ [redacted] សាវ៉ែន,ឈ្មោះ [redacted] មុន្នី ,ឈ្មោះ [redacted] សីហា ,ឈ្មោះ [redacted] លីហៀង ,ឈ្មោះ [redacted] ហេង និង ឈ្មោះ [redacted] សាវី ធ្វើឡើងក្នុងកំណត់ច្បាប់ សាលាឧទ្ធរណ៍ទទួលជំនុំជម្រះបានយោងមាត្រា ៣៨២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

២- ជនជាប់ចោទឈ្មោះ [redacted] នាង ហៅ [redacted] វណ្ណដា បានឆ្លើយសារភាពនាសវនាការសាលាឧទ្ធរណ៍ថា ខ្លួនត្រូវបានជាប់ឃុំនៅប្រទេសថៃចំនួន ២៥ឆ្នាំ ពីបទៈ គ្រឿងញៀន តាំងពីថ្ងៃទី ០៣ ខែ ៨ ឆ្នាំ ២០០៨ រហូតដល់ឆ្នាំ ២០១៣ ត្រូវបានបញ្ជូនមកពន្ធនាគារប្រទេសកម្ពុជា ។ ក្នុងអំឡុងខែ កុម្ភៈ ឆ្នាំ ២០១៦ ខ្លួនបានចាប់ផ្តើមទិញថ្នាំញៀនពីឈ្មោះ វៃយ៍ ដែលជាជនជាតិថៃស្នាក់នៅប៉ោយប៉ែត យកមកលក់បន្តឲ្យឈ្មោះ [redacted] វុហ្សា បានចំនួនបួនដង ដែលលើកទី១ មានតម្លៃ ៨០០.០០០៛ (ប្រាំបីសែនរៀល) ,លើកទី២ មានតម្លៃ ៨០០$(បួនរយដុល្លាអាមេរិក) ,លើកទី៣ មានតម្លៃ ៦០០$ (ប្រាំមួយរយដុល្លាអាមេរិក) និង លើកទី៨ មានតម្លៃ៦០០$(ប្រាំមួយរយដុល្លាអាមេរិក) ។ រាល់ការយកគ្រឿងញៀនទៅឲ្យឈ្មោះ [redacted] វុហ្សា គឺខ្លួនឲ្យប្អូនថ្លៃខ្លួនឈ្មោះ [redacted] សាវ៉ែន ជាអ្នកយកទៅឲ្យ ហើយពេលបើកលុយពីឈ្មោះ [redacted] វុហ្សា ជួនកាលឲ្យប្អូនថ្លៃរបស់ខ្លួនឈ្មោះ [redacted] សាវ៉ែន ទៅបើកឲ្យ ដោយខ្លួនឲ្យលេខទូរស័ព្ទទៅ ។ ចំណែកឯឈ្មោះ [redacted] សាវី ,ឈ្មោះ [redacted] លីហៀង ឈ្មោះ [redacted] សីហា និង ឈ្មោះ [redacted] ហេង គឺធ្វើការនៅរោងសិប្បកម្មជាមួយគ្នា និង ហ្វបចុកនៅកន្លែងធ្វើការងារផងដែរ ។ ប៉ុន្តែអ្នកទាំងអស់គ្នាពុំបានដឹងថាខ្លួនរកស៊ីជួញដូរគ្រឿងញៀនក្នុងពន្ធនាគារទេ ។ រីឯលុយកាក់ដែលចំណាយលើការហ្វបចុក គឺបានរៃអង្គាសគ្នា ។ ចំណែកឯលុយដែលខ្លួនបានធ្វើផ្ទះជូលហើយឲ្យប្រពន្ធខ្លួនគ្រប់គ្រងនោះ គឺខ្លួនបានពីការលក់ដីរបស់ខ្លួននៅភូមិ អូរដារលើ ឃុំ បឹងរាំង ស្រុក កំរៀង ខេត្ត បាត់ដំបង បានតម្លៃ ៨៨០០០០០(បួនលានប្រាំបីសែន)បាត ដែលស្មើនឹង១៣៧០០០(មួយម៉ឺនបីពាន់ប្រាំពីររយ)ដុល្លាអាមេរិកកាលពីឆ្នាំ ២០១៣ ។ ប៉ុន្តែជនជាប់ចោទក៏បានបញ្ជាក់ផងដែរថា ដីដែលលក់ខាងលើ គឺក្នុងអំឡុងដែលខ្លួនជាប់ពន្ធនាគារនៅប្រទេសថៃ ខ្លួនបានផ្ទេរទៅឲ្យម្ដាយ ហើយកិច្ចសន្យាលក់ដីនេះក៏ម្ដាយជាអ្នកលក់ដែរ ។ ដូចនេះឃើញថា ជនជាប់ចោទឈ្មោះ [redacted] នាង ពុំមានភស្តុតាងអ្វីយកមកបញ្ជាក់ថា ដីដែលបានលក់ខាងលើជាកម្មសិទ្ធិរបស់ខ្លួនឡើយ ។ លើកដំបូងខ្លួន បានឲ្យលុយចំនួន ២០៥០០ដុល្លាអាមេរិកទៅប្រពន្ធឈ្មោះ [redacted] មន្នី ដើម្បីទិញដីសម្រាប់ធ្វើផ្ទះជូលស្ថិតនៅភូមិ ទឹកថ្លា សង្កាត់ ទឹកថ្លា ក្រុងសិរីសោភ័ណ ខេត្ត បន្ទាយមានជ័យ។ បន្ទាប់មកទៀតខ្លួនបានឲ្យលុយទៅប្រពន្ធឈ្មោះ [redacted] មន្នី



Scanned with CamScanner

ជាបន្តបន្ទាប់ដើម្បីសាងសង់ផ្ទះផ្ទលនេះ រហូតដល់អស់ប្រាក់ប្រហែល១៥០០០០(ដប់បួនម៉ឺន)ដុល្លារអាមេរិក ដោយរួមទាំងថ្លៃទិញដីផង ។

៣- តាមចម្លើយជនជាប់ចោទរបស់ឈ្មោះ [redacted] ហារ៉ែន បានឆ្លើយសារភាពនាពេលសវនាការសាលាឧទ្ធរណ៍ថា ប្តឹងឧទ្ធរណ៍មកនេះ ខ្លួនមិនសុខចិត្តនឹងការកាត់ទោស ខ្លួនដែលខ្លួនបានយកទៅឲ្យគេបានតែពីរដង ។ ខ្លួនមិនចេះប្រើ និង មិនរកទេគ្រឿងញៀន គឺឈ្មោះ [redacted] នាង ជាអ្នកប្រើខ្លួនឲ្យទៅយកពីម្នាក់ថៃពីប៉ោយប៉ែតឲ្យឈ្មោះ [redacted] រ៉ូហ្សា នៅក្នុងទីរួបខេត្ត បន្ទាយមានជ័យ ,ខ្លួនកាន់គ្រឿងញៀននេះតម្លៃវាប្រហែលជាចិតសិបម៉ឺនរៀល ,ឈ្មោះ [redacted] រ៉ូហ្សា ឲ្យលុយនៅពេលដែលខ្លួនយកឥវ៉ាន់ឲ្យឈ្មោះ [redacted] រ៉ូហ្សា នៅពេលឈ្មោះ [redacted] នាង គាត់ប្រើ គឺតែពីរដងគត់ ឯប្រាក់ឈ្មោះ [redacted] នាង និង ឈ្មោះ [redacted] រ៉ូហ្សា ខ្លួនអត់ដឹងផង គាត់ឲ្យចាយត្រឹម បួនប្រាំម៉ឺន ។ ឈ្មោះ [redacted] សារ៉ែន ឆ្លើយថា ខ្លួន និង ឈ្មោះ [redacted] មន្នី ចូលឆែកបន្ទប់ ចូលរួមជាមួយនឹងសមត្ថកិច្ច ,ពេលចូលឆែកនោះ ម្ចាស់បន្ទប់មិននៅទេ មិនចាំរឿងពេលចូលរួមឆែកបន្ទប់ ថា បានផ្តិតមេដៃឬអត់ទេ ។ សំណូមពរបន្ធូរបន្ថយទោសឆាប់បានចេញទៅផ្ទះ ។

៤- តាមចម្លើយរបស់ឈ្មោះ [redacted] លីហៀង បានឆ្លើយសារភាពនាពេលសវនាការសាលាឧទ្ធរណ៍ថា ខ្លួនធ្លាប់ជាប់ពន្ធនាគារនៅថៃ ខ្លួនប្តឹងឧទ្ធរណ៍មកនេះ ដោយមូលហេតុ ខ្លួនអត់ដឹងអ្វីទាំងអស់ ,ពេលផ្ទេរពីថៃមកឲ្យខ្លួននៅបន្ទប់មួយ ដល់ពេលគេបញ្ចូល បន្ទប់ទៅតាមទោស ដោយបន្ទប់ខ្លួនសុទ្ធតែគ្រឿងញៀនទាំងអស់ ឯឈ្មោះ [redacted] សារី វេរលុយឲ្យឈ្មោះ [redacted] ណារ៉ែន ជាលុយទិញម្ហូប ,ខ្លួនមិនបានដឹងរឿងទេ ក្រៅពីការខាត់គុ-ទូ ពេលចេញទៅខាងក្រៅ ។ ពេលសមត្ថកិច្ចឆែកឆេរ មានតែឈ្មោះ [redacted] សារ៉ែន មេដែលចូលឆែកបន្ទប់ ។ ខ្លួន ជាប់ពន្ធនាគារនៅថៃ៨ឆ្នាំជាង បានស្គាល់ឈ្មោះ [redacted] ណារ៉ែន ដោយសារពួកម៉ាកខ្លួននាំស្គាល់តាមទូរស័ព្ទ ។ ក្រោយទាក់ទងបានមួយរយៈមក ស្គាល់ឈ្មោះ [redacted] នាង បានណែនាំឲ្យជួលផ្ទះឈ្មោះ [redacted] មន្នី ជាប្រពន្ធ [redacted] នាង ។ សំណូមពរសុំរួចផុតពីការចោទ ព្រោះខ្លួនមិនបានធ្វើ ។

៥- តាមចម្លើយរបស់ឈ្មោះ [redacted] សារី បានឆ្លើយសារភាពនាពេលសវនាការសាលាឧទ្ធរណ៍ថា ខ្លួនមកមុនគាត់ ជាប់ទោស២៥ឆ្នាំដូចគ្នា តែខុសគ្នា ដោយ មុនដំបូងនៅបន្ទប់មួយទេ តែនៅពេលតម្រូវឲ្យដាក់អ្នកទោសធ្ងន់បន្ទប់មួយផ្សេង ទើបខ្លួនត្រូវគេឲ្យ ដូរបន្ទប់តាមទោស ២៥ឆ្នាំ ។ ឈ្មោះ [redacted] រ៉ូហ្សា ធ្លាប់ឃើញកាលនៅពន្ធនាគារ ដល់ពេលចេញ ទៅខ្លួនមិនដែលឃើញទេ ។ មានគេនៅថៃរាប់អានគ្នា អាណិតផ្ញើលុយឲ្យខ្លួនចាយ, ផ្ញើម្តងមួយម៉ឺន បាតប្រហែលពីរបីខែម្តង ផ្ញើតាមរយៈបងប្អូននៅខ្មែរ ហើយខ្លួនពឹងឲ្យបងប្អូនជួយបើកឲ្យ។ ឈ្មោះ [redacted] ណារ៉ែន បើកឲ្យដោយគាត់ជាសង្សាររបស់ឈ្មោះ [redacted] លីហៀង អញ្ចឹងពឹងគាត់ឲ្យបើកឲ្យទៅ ទណ្ឌកម្មខ្លួនបានអនុវត្តរួចអស់ហើយ សព្វថ្ងៃនេះជាប់តែរឿងនេះ ថ្ងៃទី ២៣-២៤ ខែ ៩ ឆ្នាំ នេះទើប ខ្លួនជាប់គ្រប់បីឆ្នាំ ។ សំណូមពរតុលាការរកយុត្តិធម៌ឲ្យខ្លួនផង ខ្លួនមិនបានធ្វើអ្វីខុស ។



Scanned with CamScanner

៦- តាមចម្លើយរបស់ឈ្មោះ [redacted] ហេង បានឆ្លើយសារភាពនាពេលសវនាការ សាលាឧទ្ធរណ៍ថា ខ្លួនជាអ្នកដាំបាយធ្វើម្ហូប មិនបានដឹងរឿងអ្វីទាំងអស់ក្នុងរឿងនេះ។ ពីដើមមកក៏ខ្លួនជាអ្នកដាំបាយធ្វើម្ហូបឲ្យអ្នកទោសដែរ ពេលគាត់ដឹងខ្លួនចេះធ្វើម្ហូប [redacted] នាង គាត់បានសុំខ្លួនទៅរោងសិប្បកម្មជួយធ្វើម្ហូបឲ្យគាត់។ ខ្លួនហ៊ានស្បថចំពោះវត្ថុស័ក្តសិទ្ធិកាច់កខ្លួន កាលបើខ្លួនដឹងរឿងនេះ។ រឿងមុនជាប់៦ឆ្នាំជិតរួចហើយ បែរជាមកជាប់រឿងនេះ ដោយមិនបានដឹងអ្វីទាល់តែសោះ ។ ចម្លើយរបស់ខ្លួននៅពេលមុនក៏បានឆ្លើយអញ្ចឹង ខ្លួនរក្សាចម្លើយដដែល។ សំណូមពរតុលាការរកយុត្តិធម៌ឲ្យខ្លួនផង ។

៧- តាមអំណានចម្លើយរបស់ឈ្មោះ [redacted] សីហា បានបញ្ជាក់ថា ខ្លួននៅបន្ទប់រួមគ្នាជាមួយគេបានយូរខែដែរហើយ ដោយខ្លួនមានតួនាទីជាអ្នកដាំបាយធ្វើម្ហូប ហើយម្ហូបគេទិញយកមកឲ្យ ហើយប៉ូលីសពន្ធនាគារយកមកឲ្យ ។ ខ្លួនមានទូរស័ព្ទមួយគ្រឿងទុកគ្រាន់ទាក់ទងម៉ែឪ បងប្អូន ។ មេក្រុមសិប្បកម្មគឺបងវាវា ([redacted]នាង) ។ រឿងលុយចេញចូលខ្លួនមិនដឹងទេ ដឹងថា រឿងលុយគឺ បងដា ចាត់ចែង ។ រឿងគាត់រកស៊ីថ្នាំញៀនខ្លួនមិនដឹងទេ ដឹងតែគាត់ជាប់គុករឿងគ្រឿងញៀន ។ ខ្លួនធ្លាប់លឺបងដា និយាយរឿង លុយទិញដី ដោយនិយាយកន្លែងសិប្បកម្មថា គាត់មានដី ។ ខ្លួនអត់ឃើញឈ្មោះ ហៀង និង ឈ្មោះ ដា និយាយគ្នាស្ងាត់ៗ ទេ។ បងដា ជាអ្នកសុំឲ្យខ្លួនចេញទៅធ្វើការនៅសិប្បកម្មជាមួយ ។

៨- តាមអំណានចម្លើយរបស់ឈ្មោះ [redacted] មុន្នី បានបញ្ជាក់ថា ខ្លួនជាប្រពន្ធ [redacted]នាង ដែលបានទំនាក់ទំនងគ្នាតាំងពីនៅថៃ ហើយក៏ជាម្ចាស់ផ្ទះជួលដែលត្រូវបានបិទផងដែរ ចំពោះលុយខ្លួនមិនមានទេ គឺជាលុយរបស់ប្តីខ្លួនឈ្មោះ [redacted]នាង ។ ដីជារបស់ឈ្មោះ [redacted]នាង ដែលបានលុយពីការលែងលះជាមួយប្រពន្ធមុន ។ ដីមានទំហំ ២៥ម៉ែត្រ គុណ ៤០ម៉ែត្រ ទិញពីរម៉ឺនដុល្លា ដោយខ្លួនជាអ្នកទិញ និង ធ្វើផ្ទះអស់តម្លៃប្រហែលជាដប់ពីរម៉ឺនដុល្លាដាក់ឈ្មោះខ្លួន តែលុយជារបស់ [redacted] នាង ទាំងអស់ ហើយលុយគឺខ្លួនទទួលពីចែពៅ ជាប្អូនគាត់ ដែលជូនកាល ពាត់វេរពាមវីង ជូនកាលយកមកឲ្យផ្ទាល់ ។ [redacted]នាង ក៏មានខ្ចីលុយពីរម៉ឺនដុល្លាពីប្រពន្ធដើមគាត់ឈ្មោះ ចែមុំ ដើម្បីយកមកឲ្យថ្លៃឥវ៉ាន់ធ្វើផ្ទះផងដែរ ដែលលុយនេះប្រពន្ធដើមគាត់យកទៅឲ្យគាត់នៅពន្ធនាគាររួច [redacted]នាង ប្រើក្មួយគាត់ឈ្មោះ [redacted] សំណាង យកមកឲ្យខ្លួន ។ ចំពោះឈ្មោះ [redacted]រ៉ូហ្សា មុនពេលកើតហេតុបានទំនាក់ទំនងមកខ្លួនខ្លះថា ជាប្រពន្ធរបស់ឈ្មោះ [redacted]នាង (ឈ្មួន វណ្ណដា) ។

៩- តាមអំណានចម្លើយរបស់ឈ្មោះ [redacted] ចំរើន បានបញ្ជាក់ថា ខ្លួនធ្លាប់ឆ្លើយសារភាពហើយ ។ ក៏ទទួលស្គាល់ការចោទប្រកាន់ដែរ ។ នៅថ្ងៃនោះមិត្តភក្តិបានគេបបួលខ្លួនទិញថ្នាំញៀនជក់ តែវាហៅប៉េអឹមមកចាប់ខ្លួន ។ ក៏សហការចាប់បន្ត តែខ្លួនមិនដែលទិញថ្នាំញៀនលក់ទេ ធ្លាប់តែប្រើប្រាស់ជាច្រើនដង ដោយខ្លួនទិញម្តងមួយកញ្ចប់តម្លៃប្រាំមួយទៅប្រាំម៉ឺនរៀល ដោយលុយចូលគ្នាហើយទៅទិញពីអ្នកណាទេ ។ ចំណែកឯឈ្មោះ [redacted]រ៉ូហ្សា ខ្លួនមិនស្គាល់ទេ ខ្លួនស្គាល់តែ



Scanned with CamScanner

ឈ្មោះ ផុន ពេលដែលខ្លួនជូនសមត្ថកិច្ចទៅរកចាប់ឈ្មោះ ផុន ៗ ក៏រត់ចោលផ្ទះ ដោយទុកទូរស័ព្ទចោល ហើយស្របពេលមាន[redacted] រ៉ូហ្សា) គេមកសមត្ថកិច្ចក៏ឲ្យខ្លួនលើកដោយបង្ខំថា ខ្លួនជាឈ្មោះ ផុន ហើយឲ្យកុម្ម៉ង់ទិញញៀនតម្លៃ៧០ម៉ឺនរៀល រួចសមត្ថកិច្ចឲ្យខ្លួនជូនទៅតាមចាប់ដោយណាត់ជួបនៅបន្ទាយនាង តែពេលទៅជួបឈ្មោះ [redacted] រ៉ូហ្សា ដឹងខ្លួនថា មិនមែនជាឈ្មោះ ផុន ក៏បានបើកឡានរត់គេច សមត្ថកិច្ចតាមចាប់ខ្លួនបាន ។ ចំពោះឈ្មោះ ផុន គឺជា[redacted]កុសល ខ្លួនស្គាល់ពេលចូលរៀនបានមួយឆ្នាំជាងតាមរយៈមិត្តភក្តិឈ្មោះ ភា ជាអ្នកណែនាំឲ្យស្គាល់ ដោយខ្លួនស្គាល់គ្រាន់តែទាក់ទងទិញថ្នាំញៀនពីវាប៉ុណ្ណោះ ។ ពេលខ្លួនទៅយកថ្នាំញៀនពីវា([redacted] កុសល) វាអត់មានម៉ូតូជិះ វាក៏ជូនទៅដោយថាទៅទិញអីហូប តែពេលទៅដល់ ខ្លួនឃើញវាយកថ្នាំញៀនលក់ឲ្យគេជាច្រើនដង ហើយគេឲ្យខ្លួនប្រើប្រាស់ថ្នាំញៀន ។

១០- តាមអំណានចម្លើយរបស់ឈ្មោះ [redacted] រ៉ូហ្សា បានបញ្ជាក់ថា ចម្លើយរបស់ខ្លួនទាំងប៉ុន្មានជាការពិត ។ ខ្លួនជួញដូរគ្រឿងញៀនបាន៨ដងហើយ ដោយដំបូងខ្លួនស្គាល់ឈ្មោះ [redacted] នាង នៅក្នុងគុក ដល់ពេលខ្លួនចេញពីគុក ខ្លួនបានទៅសួរសុខទុក្ខឈ្មោះ[redacted] នាង ក្នុងពន្ធនាគារ ហើយគាត់កុហកខ្លួនថា គាត់មិនអានប្រពន្ធទេ បែរជាគាត់ទាក់ទងខ្លួនឲ្យជួយកាន់ថ្នាំញៀនយកទៅលក់ឲ្យម៉ូយរបស់គាត់ដើម្បីបានលុយយកមកឲ្យគាត់វិញទាំងអស់ ។ តែលើកចុងក្រោយនេះដោយសារតែឈ្មោះ [redacted] នាង មិនបានឲ្យលុយខ្លួនពីរបីខែមកហើយ ទើបខ្លួនយកលក់ដោយខ្លួនឯង ដើម្បីបានលុយខ្លះ លក់ថ្នាំឲ្យ[redacted] នាង ម្តង ៗ មានទម្ងន់ប្រហែលជា៦-៧ជីខ្មែរ ជាលុយបានបីលានរៀលជាង ដោយខ្លួនពរក់ឲ្យអ្នកប្រើប្រាស់ ។ ចំពោះថ្នាំញៀន គឺឈ្មោះ [redacted] នាង ឲ្យប្អូន និងកូនចៅគាត់មានឈ្មោះ ផល និង ឈ្មោះ សារ៉ែន ជាប្អូនថ្លៃគាត់យកមកឲ្យខ្លួន ចំណែកលុយថ្លៃថ្នាំញៀន ជូនកាលខ្លួនយកមកឲ្យក្នុងពន្ធនាគារ ជូនកាលវេរតាមវីង ហើយគាត់ឲ្យប្អូនថ្លៃគាត់បើកឲ្យ ហើយ [redacted] នាង ទំនាក់ទំនងជាមួយខ្លួន តាមរយៈទូរស័ព្ទដែលឈ្មោះ[redacted] នាង អាចប្រើបានចន្លោះពីម៉ោង៦ល្ងាចដល់ម៉ោង៦ព្រឹក និង ពេលថ្ងៃត្រង់ ចន្លោះពីម៉ោងដប់ពីរដល់ម៉ោងពីរ ដែលការទាក់ទងគឺនិយាយរឿងថ្នាំញៀន ព្រោះខ្លួនមានទំនាក់ទំនងស្នេហាជាមួយឈ្មោះ[redacted] នាង ។ ពេលខ្លួនវេរលុយឲ្យឈ្មោះ[redacted] នាង ហៅលេខកូដឲ្យឮសម្លេងមនុស្សស្រី តែមិនដឹងថា ជានរណាទេ ។ ចំណែកប្រពន្ធ[redacted] នាង ខ្លួនទើបតែស្គាល់ពេលដែលសមត្ថកិច្ចចុះឆែកឆេរផ្ទះ ។ ចំពោះឈ្មោះ ផុន ហៅ [redacted] កុសល ខ្លួនមិនស្គាល់ទេ ។ ចំពោះរថយន្តខ្លួន គឺអ្នកចិញ្ចឹមខ្លួនពីមុនដែលស្លាប់ទៅហើយជាអ្នកទិញឲ្យ ដែលឡាននេះខ្លួនយកដឹកថ្នាំញៀនម្តងម្កាល ។ ជនជាប់ចោទឈ្មោះ[redacted] សារី ថាពេលខ្លួនចេញទៅវិញមិនឲ្យរួចខ្លួនទេ ព្រោះដោយសារតែខ្លួនធ្វើឲ្យមានការពាក់ព័ន្ធដល់រូបគាត់ និងធ្វើឲ្យគាត់ខាតលុយ ឈ្មោះ សារី នេះមានទំនាក់ទំនងជាមួយឈ្មោះ [redacted] នាង ហៅ ដា។ ខ្លួនមានការភ័យខ្លាចចំពោះសុវត្ថិភាពព្រោះសូម្បីតែប្អូនថ្លៃរបស់ [redacted] នាង ឈ្មោះ សារ៉ែន បានបោះពាក្យថា ចេញទៅវិញគឺបានស៊ីគ្រាប់សំណរហើយ សូម្បី [redacted] នាង ក៏និយាយដែរថា ឲ្យតែនៅខេត្ត បន្ទាយ



Scanned with CamScanner

មានជ័យ បាត់ដំបង និង ឲ្យកូនទៅតាមរកឃើញ ។ ហើយក្នុងពន្ធនាគារដោយសារតែខ្លួន ឆ្លើយដាក់ [redacted] នាង ប្រធានពន្ធនាគារខឹងនឹងខ្លួន តាមសង្កាត់ថា ដោយសារតែខ្លួនធ្វើឲ្យបាត់ចំណូលក្នុងពន្ធនាគារ ។

១១- តាមកំណត់ហេតុចាប់យកវត្ថុតាងលេខ: ៥២/២០១៦ កចវ ចុះថ្ងៃទី ១៨ ខែ ៩ ឆ្នាំ ២០១៦ របស់ការិយាល័យបទល្មើសគ្រឿងញៀននៃកងរាជអាវុធហត្ថខេត្ត បន្ទាយមានជ័យ បានធ្វើការដកហូតគ្រឿងញៀមពីឈ្មោះ [redacted] ចំរើន ទម្ងន់០,៥២ក្រាម ។

- តាមកំណត់ហេតុចាប់យកវត្ថុតាងលេខ: ៣១/២០១៦ កចវ ចុះថ្ងៃទី ១៩ ខែ ៩ ឆ្នាំ ២០១៦ របស់ការិយាល័យបទល្មើសគ្រឿងញៀននៃកងរាជអាវុធហត្ថខេត្ត បន្ទាយមានជ័យ បានធ្វើការដកហូតគ្រឿងញៀមពីឈ្មោះ [redacted] រ៉ូហ្វា ទម្ងន់ ១៨,០២ក្រាម ។

- តាមកំណត់ហេតុនៃកនេរលើកទី១ ចុះថ្ងៃទី ១៩ ខែ ៩ ឆ្នាំ ២០១៦ និង លើកទី២ ចុះថ្ងៃទី ២១ ខែ ៩ ឆ្នាំ ២០១៦ របស់ការិយាល័យគ្រឿងញៀននៃកងរាជអាវុធហត្ថខេត្ត បន្ទាយមានជ័យ ពុំបានធ្វើការដកហូតឡើយ នេះបញ្ជាក់ឲ្យឃើញថា ជនជាប់ចោទឈ្មោះ [redacted] មុន្នី ពុំមានគ្រឿងញៀនឡើយ ។

- តាមកំពកត់ហេតុដកហូតសម្ភារៈចុះថ្ងៃទី ១៩ ខែ ៩ ឆ្នាំ ២០១៦ របស់ការិហេល័យគ្រឿងញៀននៃកងរាជអាវុធហត្ថខេត្ត បន្ទាយមានជ័យ ពុំបានដកហូតគ្រឿងញៀនពីជនជាប់ចោទឈ្មោះ [redacted] សីហា ឡើយ ។

- តាមកំណត់ហេតុដកហូតសម្ភារៈចុះថ្ងៃទី ១៩ ខែ ៩ ឆ្នាំ ២០១៦ របស់ការិយាល័យគ្រឿងញៀននៃកងរាជអាវុធហត្ថខេត្ត បន្ទាយមានជ័យ ពុំបានដកហូតគ្រឿងញៀនពីជនជាប់ចោទឈ្មោះ [redacted] នាង ហៅ [redacted] វណ្ណដា ឡើយ ។

- តាមកំណត់ហេតុដកហូតសម្ភារៈចុះថ្ងៃទី ១៩ ខែ ៩ ឆ្នាំ ២០១៦ របស់ការិយាល័យគ្រឿងញៀននៃកងរាជអាវុធហត្ថខេត្ត បន្ទាយមានជ័យ ពុំបានដកហូតគ្រឿងញៀនពីជនជាប់ចោទឈ្មោះ [redacted] លីហៀង ឡើយ ។

- តាមកំណត់ហេតុដកហូតសម្ភារៈចុះថ្ងៃទី ១៩ ខែ ៩ ឆ្នាំ ២០១៦ របស់ការិយាល័យគ្រឿងញៀននៃកងរាជអាវុធហត្ថខេត្ត បន្ទាយមានជ័យ ពុំបានដកហូតគ្រឿងញៀនពីជនជាប់ចោទឈ្មោះ [redacted] សារ៉ែន ឡើយ ។

- តាមកំណត់ហេតុឃាត់ខ្លួនលេខ: ៥៨/២០១៦ កឃខ ចុះថ្ងៃទី ១៩ ខែ ៩ ឆ្នាំ ២០១៦ របស់ការិយាល័យបទល្មើសគ្រឿងញៀននៃកងរាជអាវុធហត្ថខេត្ត បន្ទាយមានជ័យ លើឈ្មោះ [redacted] ហេង ពុំបានរកឃើញគ្រឿងញៀនទេ ។



Scanned with CamScanner

- តាមកំណត់ហេតុឃាត់ខ្លួនលេខ: ៤១/២០១៦ កយឌ ចុះថ្ងៃទី ១៥ ខែ ៩ ឆ្នាំ ២០១៦ របស់ការិយាល័យបទល្មើសគ្រឿងញៀននៃកងរាជអាវុធហត្ថខេត្ត បន្ទាយមានជ័យ លើឈ្មោះ [redacted] សាវី ពុំបានរកឃើញគ្រឿងញៀនទេ ។

- តាមកំណត់ហេតុឆែកឆេរចុះថ្ងៃទី ១៥ ខែ ៩ ឆ្នាំ ២០១៦ បានចុះឆែកឆេរបន្ទប់លេខ: ២ នៃអាគារ ក នៅពន្ធនាគារខេត្ត បន្ទាយមានជ័យ ពុំបានរកឃើញគ្រឿងញៀនឡើយ ប៉ុន្តែបានដកហូតសម្ភារៈរួមមាន: ទូរស័ព្ទសរុបចំនួន១២គ្រឿង, ឧបករណ៍ផ្ទុកអគ្គីសនីសម្រាប់បញ្ចូលថ្មចំនួន ០៥គ្រឿង ,ម៉ាស៊ីនMP4 ចំនួន០១គ្រឿង ,ខ្សែឆ្នាំងសាកទូរស័ព្ទខ្សែភ្លើង និង ព្រីភ្លើងមួយចំនួន ។ បន្ទាប់មកបានឆែកឆេរនៅរោងសិប្បកម្មនៃពន្ធនាគារខេត្ត បន្ទាយមានជ័យ បានដកហូតទូរសព្ទ័ម៉ាកណូគាចំនួន០៣គ្រឿង ,ទូរសព្ទ័ម៉ាករាយហ្វូនចំនួន០១គ្រឿង ប៉ុន្តែពុំបានធ្វើការដកហូតគ្រឿងញៀនឡើយ ។

១៣- កាលពីថ្ងៃទី ១៥ ខែ ៩ ឆ្នាំ ២០១៦ មន្ត្រីការិយាល័យបទល្មើសគ្រឿងញៀននៃកងរាជអាវុធហត្ថខេត្ត បន្ទាយមានជ័យ បានអនុវត្តវិធានញុះញង់ឲ្យលក់ដោយខុសច្បាប់នូវសារធាតុញៀន ដោយឃាត់ខ្លួនជនសង្ស័យឈ្មោះ [redacted] ចំរើន ភេទប្រុស អាយុ ១៧ឆ្នាំ ដកហូតគ្រឿងញៀនចំនួន០,៨២ក្រាម រួចបន្តទៅចាប់បានជនសង្ស័យឈ្មោះ [redacted] វ៉ាហ្សា ដោយដកហូតបានវត្ថុតាងគ្រឿងញៀនចំនួន១៨,០១ក្រាម ហើយជនសង្ស័យឈ្មោះ [redacted] វ៉ាហ្សា បានសហការជាមួយសមត្ថកិច្ច រួចបន្តឃាត់ខ្លួនជនជាប់ចោទឈ្មោះ [redacted] នាង ហៅ [redacted] វណ្ណា , ឈ្មោះ [redacted] មុន្នី ,ឈ្មោះ [redacted] សាវ៉ែន ,ឈ្មោះ [redacted] លីហៀង ,ឈ្មោះ [redacted] ហោង ,ឈ្មោះ [redacted] សីហា និង ឈ្មោះ [redacted] សាវី ប៉ុន្តែពុំបានធ្វើការដកហូតវត្ថុតាងដូចជាគ្រឿងញៀនអ្វីឡើយ។

១៤- ការឆែកឆេរទៅលើបន្ទប់ជួលស្ថិតនៅភូមិ ទឹកថ្លា សង្កាត់ ទឹកថ្លា ក្រុង សិរីសោភ័ណ ខេត្ត បន្ទាយមានជ័យ ដែលមានឈ្មោះ [redacted] មុន្នី ជាអ្នកគ្រប់គ្រង និង ជាម្ចាស់ផ្ទះ គឺពុំបានដកហូតនូវវត្ថុតាងជាគ្រឿងញៀនឡើយ ដូចនេះឃើញថា ជនជាប់ចោទឈ្មោះ [redacted] មន្នី ពុំមានពិរុទ្ធភាព ពីបទចោទប្រកាន់ គឺបទជួញដូរដោយខុសច្បាប់នូវសារធាតុញៀនឡើយ ។ ប៉ុន្តែនៅពេលដែលឈ្មោះ [redacted] មន្នី ទទួលប្រាក់ពីប្តីឈ្មោះ [redacted] នាង ដើម្បីយកទៅទិញដី និង សាងសង់ផ្ទះជួលខាងលើ គឺក្នុងអំឡុងពេលដែលជនជាប់ចោទឈ្មោះ [redacted] នាង កំពុងជាទណ្ឌិតជាប់ក្នុងពន្ធនាគារ ហើយប្រាក់ដែលឈ្មោះ [redacted] នាង ប្រគល់ទៅឲ្យឈ្មោះ [redacted] មន្នី ដើម្បីទិញដី និង ធ្វើផ្ទះជួលខាងលើ គឺបានមកពីការជួញដូរគ្រឿងញៀន ហើយជនជាប់ចោទបានបង្វែរប្រាក់ជាប្រាក់ដែលខ្លួនបានលក់ដីនៅភូមិ អូរដាលើ ឃុំ បឹងរាំង ស្រុក កំរៀង ខេត្ត បាត់ដំបង ដែលជាអំពើចូលរួមសំអាតប្រាក់ជាមួយជនជាប់ចោទឈ្មោះ [redacted] នាង ។

១៥- ជនជាប់ចោទឈ្មោះ [redacted] នាង បានឆ្លើយសារភាពនូវសកម្មភាពប្រព្រឹត្តបទល្មើសរបស់ខ្លួន ដែលចម្លើយនេះស្របទៅនឹងចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] វ៉ាហ្សា ដែល



Scanned with CamScanner

ជាអ្នកយកគ្រឿងញៀនពីជនជាប់ចោទឈ្មោះ [redacted] នាង ទៅលក់បន្ត និង តាមចម្លើយសារភាពរបស់ជនជាប់ចោទឈ្មោះ [redacted] នាង បានឆ្លើយដាក់បន្ទុកទៅលើជនជាប់ចោទដែលជាប្អូនថ្លៃរបស់ខ្លួន ប៉ុន្តែពុំបានឆ្លើយដាក់បន្ទុកទៅលើជនជាប់ចោទឈ្មោះ [redacted] លីហៀង ,ឈ្មោះ [redacted] សីហា, ឈ្មោះ [redacted] ហេង និង ឈ្មោះ [redacted] សាវី ឡើយ ហើយជនជាប់ចោទឈ្មោះ [redacted] លីហៀង ,ឈ្មោះ [redacted] សីហា ,ឈ្មោះ [redacted] ហេង និង ឈ្មោះ [redacted] សាវី ក៏បានឆ្លើយបដិសេធនូវអង្គហេតុនេះចាប់តាំងពីពេលឃាត់ខ្លួននៅមន្ត្រីនគរបាលយុត្តិធម៌រហូតនាពេលសវនាការសាលាឧទ្ធរណ៍ ។ ម៉្យាងទៀត តាមកំណត់ហេតុផែកឆេរ និង ដកហូតវត្ថុតាង ដែលធ្វើឡើង និង ដឹកនាំដោយអយ្យការអមសាលាដំបូងខេត្ត បន្ទាយមានជ័យ ក៏ពុំបានធ្វើការដកហូតគ្រឿងញៀនពីជនជាប់ចោទឡើយ ។ ជាពិសេស ក្រុមប្រឹក្សាជឿជាក់លើចម្លើយដោះបន្ទុករបស់ជនជាប់ចោទឈ្មោះ [redacted] នាង ដោយហេតុថា ជនជាប់ចោទទាំងបួននាក់នេះពុំជាប់សាច់ញាតិជាមួយជនជាប់ចោទឈ្មោះ [redacted] នាង ហើយជនជាប់ចោទឈ្មោះ [redacted] នាង បានឆ្លើយដាក់បន្ទុកទៅលើឈ្មោះ [redacted] សារ៉ែន ដែលជាប្អូនថ្លៃរបស់ខ្លួនទៅវិញ ។ រីឯជនជាប់ចោទឈ្មោះ [redacted] សារ៉ែន ក៏បានឆ្លើយសារភាពដែរថា ខ្លួនពិតជាបានយកគ្រឿងញៀនទៅឲ្យឈ្មោះ [redacted] រ៉ូហ្សា តាមបញ្ជាតាមទូរស័ព្ទរបស់បងថ្លៃរបស់ខ្លួនឈ្មោះ [redacted] នាង ដែរ ។ ម៉្យាងទៀតពាក់ព័ន្ធទៅនឹងបទចោទប្រកាន់ខាងលើជនជាប់ចោទឈ្មោះ [redacted] សារ៉ែន ឈ្មោះ [redacted] លីហៀង ឈ្មោះ [redacted] ហេង និង ឈ្មោះ [redacted] សាវី ថា បានប្រព្រឹត្តអំពើសំអាតប្រាក់ ក៏ពុំមានអង្គហេតុ និង ភស្តុតាងណាបញ្ជាក់ដែរ ។

១៦- រីឯជនជាប់ចោទឈ្មោះ [redacted] នាង ដែលបានឆ្លើយបញ្ជាក់ថា ចំពោះផ្ទះជួល ស្ថិតនៅភូមិ ទឹកថ្លា សង្កាត់ ទឹកថ្លា ក្រុង សិរីសោភ័ណ ខេត្ត បន្ទាយមានជ័យ គឺបានមកពីការលក់ផ្ទះ និង ដីស្ថិតនៅភូមិ អូរដារលើ ឃុំ បឹងរាំង ស្រុក កំរៀង ខេត្ត បាត់ដំបង នោះ ពុំមានអ្វីយកមកបញ្ជាក់ថា ជាទ្រព្យសម្បត្តិរបស់ខ្លួនដែលតាមភស្តុតាងដែលបង្ហាញដោយជនជាប់ចោទឃើញថាជាទ្រព្យសម្បត្តិរបស់ម្តាយ ។ ដូចនេះឃើញថា ជនជាប់ចោទបានបង្វែរប្រាក់ដែលបានមកពីការជួញដូរគ្រឿងញៀន ដើម្បីយកប្រាក់ទៅធ្វើផ្ទះជួលខាងលើ គឺជាអំពើសំអាតប្រាក់ ។

១៧- តំណាងមហាអយ្យការបានធ្វើសេចក្តីសន្និដ្ឋានថា ក្នុងសំណុំរឿងនេះបើពិនិត្យទៅលើអង្គហេតុមានការច្រឡូកច្របល់ដែលមានមនុស្សដល់ទៅដប់នាក់ពាក់ព័ន្ធសំខាន់ក្នុងរឿងមានតែឈ្មោះ [redacted] នាង បន្ទាប់ឈ្មោះ [redacted] សារ៉ែន ចំណែកអ្នកដទៃទៀតហាក់បីមិនពាក់ព័ន្ធទាល់តែសោះ ក្នុងនោះខ្លះជាចុងភៅមិនដឹងអីទាល់តែសោះជាប់ប្រាំឆ្នាំដែរ អ្នកពាក់ព័ន្ធដែលត្រូវនោះមានឈ្មោះ [redacted] សារ៉ែន និង ឈ្មោះ [redacted] នាង ,ចំពោះការរឹបអូសវិញក៏មានលក្ខណៈមិនច្បាស់លាស់ មិនរកឲ្យឃើញថា ទ្រព្យនោះមានមុនការរកស៊ីគ្រឿងញៀន ឬ បានក្រោយរកស៊ីគ្រឿងញៀន ចាំខ្លួនធ្វើសេចក្តីសន្និដ្ឋាន ខ្លះ ។ ដើម្បីដាក់ជូនតាមក្រោយ ខ្លួនសុំទទួចក្រុមប្រឹក្សាបែងចែកអង្គហេតុឲ្យបានសុក្រឹត្យ រកយុត្តិធម៌ឲ្យជនជាប់ចោទ អ្នកប្រព្រឹត្តត្រូវតែជាប់ទោស អ្នកមិនប្រព្រឹត្ត



Scanned with CamScanner

ត្រូវតែរួចខ្លួន ដូចជាឈ្មោះ [redacted] ហោង ឯអ្នកដទៃទៀតសុំពិចារណាលើទណ្ឌកម្ម គួរតែបន្ធូរបន្ថយ ហើយឈ្មោះ [redacted] លីហៀង ក៏គួរតែរួចផុតពីបទចោទផងដែរ សូមបញ្ជាក់ថា ទ្រព្យសម្បត្តិនេះមិនជាប់នឹងការលាងលុយទេ បើពិនិត្យទៅលើអង្គហេតុនេះ ។

១៨- លោក [redacted] ឧត្តម មេធាវីការពារឲ្យជនជាប់ចោទឈ្មោះ [redacted] ប៊ីហៀង ធ្វើសេចក្តីសន្និដ្ឋានការពារថា តាមការសួរដេញដោលចំពោះមុខបញ្ជាក់បានថាកូនក្តីខ្លួន មិនបានប្រព្រឹត្តដូចការចោទប្រកាន់ទេ គ្រាន់តែជាអ្នករស់នៅបន្ទប់ជាមួយឈ្មោះ [redacted] នាង ដូចមានការ បញ្ជាក់ពីជនផ្សេងទៀតក៏ថា កូនក្តីខ្លួនមិនពាក់ព័ន្ធនឹងគ្រឿងញៀននេះទេ មានតែការរស់នៅតែមួយគត់ដែលត្រូវកូនក្តីខ្លួនបានគេចោទប្រកាន់មកនេះតែម្តង សំណូមពរអនុញ្ញាតឲ្យកូនក្តីខ្លួនរួចផុតពីបទចោទ។

១៩- លោក [redacted] ភក្តី មេធាវីការពារឲ្យជនជាប់ចោទឈ្មោះ [redacted] នាង ,ឈ្មោះ [redacted] សារ៉ែន ,ឈ្មោះ [redacted] បុទ្ធី ,ឈ្មោះ [redacted] សីហា ធ្វើសេចក្តីសន្និដ្ឋានការពារថា ខ្លួនគាំទ្រទៅលើសេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ តាមអង្គហេតុនៃរឿងនេះគឺកើតឡើងតាមវិធានញុះញង់ដែលចេញពីឈ្មោះ [redacted] ចំរើន ហើយបន្តជាហូរហែនូវហេតុទាំងនេះ ដែលកើតជាមួយនឹងឈ្មោះ [redacted] រ៉ូហ្សា ម្នាក់គត់ ហើយកូនក្តីខ្លួនឈ្មោះ [redacted] នាង ក៏បានទទួលស្គាល់ផងដែរថា ដោយសារតែគាត់ម្នាក់គត់ធ្វើឲ្យអ្នកដទៃជាប់ដោយសារគាត់ជាមួយឈ្មោះ [redacted] ហ្សា ដូចនេះសូមក្រុមប្រឹក្សាពិចារណាតាបមាត្រា ៩៣ នៃច្បាប់ ស្តីពីការគ្រប់គ្រងសម្រាលឲ្យគាត់ ពីព្រោះកូនក្តីខ្លួន [redacted] នាង ដែលបានទទួលស្គាល់កំហុស និង មានការសោកស្តាយយ៉ាងខ្លាំង និង ចំណុចរឹបអូសទ្រព្យសម្បត្តិសុំពិចារណាផងដែរ ,ចំពោះឈ្មោះ [redacted] សីហា និង ឈ្មោះ [redacted] សារី វិញ គឺគាត់បានបញ្ជាក់ហើយថា មិនបានដឹងរឿង ឬ សកម្មភាពជួញដូរគ្រឿងញៀន គាត់គ្រាន់តែរួមបន្ទប់តែមួយជាមួយឈ្មោះ [redacted] នាង គាត់មានពាក់ព័ន្ធតែបន្តិចរឿងវេរលុយ គាត់បញ្ជាក់រួចហើយគឺវេរលុយទិញម្ហូប សំណូមពរសុំឲ្យកូនក្តីខ្លួនរួចពីបទចោទប្រកាន់ ។

២០. លោក [redacted] សុភា មេធាវីការពារឲ្យជនជាប់ចោទឈ្មោះ [redacted] សារី និង ឈ្មោះ [redacted] សីហា ធ្វើសេចក្តីសន្និដ្ឋានការពារថា តុលាការបានចោទប្រកាន់លើកូនក្តីខ្លួនឈ្មោះ [redacted] សារី ពីបទ: ជួញដូរដោយខុសច្បាប់ ប្រព្រឹត្តនៅពន្ធនាគារខេត្ត បន្ទាយមានជ័យ កាលពីថ្ងៃទី ១៨ ខែ កញ្ញា ឆ្នាំ ២០១៦ និង ឈ្មោះ [redacted] សីហា ពីបទ: សមគំនិតក្នុងអំពើជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅចំណុចពន្ធនាគារខេត្ត បន្ទាយមានជ័យ ដូចគ្នា គឺកូនក្តីខ្លួនតាំងពីសាលាដំបូងរហូតមក បានឆ្លើយបញ្ជាក់ឆ្លើយថា គាត់មិនបានប្រព្រឹត្តដូចការចោទប្រកាន់នេះទេ ពួកគាត់ ទើបតែមកនៅបន្ទប់ជាមួយឈ្មោះ [redacted] នាង ពីរ-បីខែប៉ុណ្ណោះ ចំពោះការវេរលុយគឺប្រពន្ធគាត់វេរមកឲ្យទិញម្ហូប មិនពាក់ព័ន្ធនឹងថ្នាំញៀនទេ សូមឯកភាពទៅនឹងសេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ សំណូមពរក្រុមប្រឹក្សាសម្រេចឲ្យកូនក្តីខ្ញុំបានរួចផុតពីបទចោទប្រកាន់ ។

២១- តាមអង្គហេតុ និង ភស្តុតាងដែលបានយល់ឃើញខាងលើបញ្ជាក់ថា:



Scanned with CamScanner

ក.គ្មានពិរុទ្ធភាពលើឈ្មោះ [redacted] លីហៀង ,ឈ្មោះ [redacted] ហេង និង ឈ្មោះ [redacted] ភារី ពីបទៈជួញដូរដោយខុសច្បាប់នូវសារធាតុញៀន និងបទៈសម្អាតប្រាក់ ប្រព្រឹត្តនៅចំណុចពន្ធនាគារ ខេត្ត បន្ទាយមានជ័យ និង ចំណុចបន្ទប់ជួលស្ថិតនៅភូមិ ទឹកថ្លា សង្កាត់ ទឹកថ្លា ក្រុង សិរីសោភ័ណ ខេត្ត បន្ទាយមានជ័យ កាលពីអំឡុងឆ្នាំ ២០១៦ ដល់ថ្ងៃទី ១៨ ខែ កញ្ញា ឆ្នាំ ២០១៦ តាមមាត្រា ៤០ កថាខណ្ឌ៣ និង កថាខណ្ឌ ៥ ចំណុច១ និង មាត្រា ៣២ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន និង មាត្រា ៤០៤ និង មាត្រា ៤០៦ នៃក្រមព្រហ្មទណ្ឌ ។

ខ.គ្មានពិរុទ្ធភាពលើឈ្មោះ [redacted] សីហា ហៅ តិត ពីបទៈ សមគំនិតក្នុងអំពើជួញដូរដោយខុសច្បាប់នូវសារធាតុញៀនប្រព្រឹត្តនៅចំណុចពន្ធនាគារខេត្តបន្ទាយមានជ័យ និង ចំណុចបន្ទប់ជួលស្ថិតនៅភូមិ ទឹកថ្លា សង្កាត់ ទឹកថ្លា ក្រុង សិរីសោ ភ័ណ ខេត្ត បន្ទាយមានជ័យ កាលពីអំឡុងឆ្នាំ ២០១៦ ដល់ថ្ងៃទី ១៨ ខែ កញ្ញា ឆ្នាំ ២០១៦ តាមមាត្រា ៤០ កថាខណ្ឌ៣ និង កថាខណ្ឌ ៥ ចំណុច១ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន និង មាត្រា ២៩ នៃក្រមព្រហ្មទណ្ឌ ។

គ.គ្មានពិរុទ្ធភាពលើឈ្មោះ [redacted] មន្នី ពីបទៈ ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅចំណុចពន្ធនាគារខេត្ត បន្ទាយមានជ័យ និង ចំណុចបន្ទប់ជួលស្ថិតនៅភូមិ ទឹកថ្លា សង្កាត់ ទឹកថ្លា ក្រុង សិរីសោភ័ណ ខេត្ត បន្ទាយមានជ័យ កាលពីអំឡុងឆ្នាំ ២០១៦ ដល់ថ្ងៃទី ១៨ ខែ កញ្ញា ឆ្នាំ ២០១៦ តាមបញ្ញត្តិមាត្រា ៤០ កថាខណ្ឌ៣ និង កថាខណ្ឌ ៥ ចំណុច១ និង មាត្រា ៣២ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

ឃ.គ្មានពិរុទ្ធភាពលើឈ្មោះ [redacted] សាវ៉ែន ពីបទៈ សម្អាតប្រាក់ ប្រព្រឹត្តនៅចំណុចពន្ធនាគារខេត្ត បន្ទាយមានជ័យ និង ចំណុចបន្ទប់ជួលស្ថិតនៅភូមិ ទឹកថ្លា សង្កាត់ ទឹកថ្លា ក្រុង សិរីសោ ភ័ណ ខេត្ត បន្ទាយមានជ័យ កាលពីអំឡុងឆ្នាំ ២០១៦ ដល់ថ្ងៃទី ១៨ ខែ កញ្ញា ឆ្នាំ ២០១៦ មាត្រា ៤០៤ និង មាត្រា ៤០៦ នៃក្រមព្រហ្មទណ្ឌ ។

ង.មានពិរុទ្ធភាពលើឈ្មោះ [redacted] មន្នី ពីបទៈ សម្អាតប្រាក់ ប្រព្រឹត្តនៅចំណុចពន្ធនាគារខេត្ត បន្ទាយមានជ័យ និង ចំណុចបន្ទប់ជួលស្ថិតនៅភូមិ ទឹកថ្លា សង្កាត់ ទឹកថ្លា ក្រុង សិរីសោ ភ័ណ ខេត្ត បន្ទាយមានជ័យ កាលពីអំឡុងឆ្នាំ ២០១៦ ដល់ថ្ងៃទី ១៨ ខែ កញ្ញា ឆ្នាំ ២០១៦ តាមបញ្ញត្តិមាត្រា ៤០៤ និង មាត្រា ៤០៦ នៃក្រមព្រហ្មទណ្ឌ ។

ច.មានពិរុទ្ធភាពលើឈ្មោះ [redacted] សាវ៉ែន ពីបទៈ ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅចំណុចពន្ធនាគារខេត្ត បន្ទាយមានជ័យ និង ចំណុចបន្ទប់ជួលស្ថិតនៅភូមិ ទឹកថ្លា សង្កាត់ ទឹកថ្លា ក្រុង សិរីសោ ភ័ណ ខេត្ត បន្ទាយមានជ័យ កាលពីអំឡុងឆ្នាំ ២០១៦ ដល់ថ្ងៃទី ១៨ ខែ កញ្ញា ឆ្នាំ ២០១៦ តាមបញ្ញត្តិមាត្រា ៤០ កថាខណ្ឌ៣ និង កថាខណ្ឌ ៥ ចំណុច១ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។



Scanned with CamScanner

ឆ.មានពិរុទ្ធភាពលើឈ្មោះ [redacted] នាង ហៅ [redacted] វណ្ណដា ពីបទ: ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន និង បទ: សម្អាតប្រាក់ ប្រព្រឹត្តនៅចំណុចពន្ធនាគារខេត្ត បន្ទាយមានជ័យ និង ចំណុចបន្ទប់ជួលស្ថិតនៅភូមិ ទឹកថ្លា សង្កាត់ ទឹកថ្លា ក្រុង សិរីសោភ័ណ ខេត្ត បន្ទាយមានជ័យ កាលពីអំឡុងឆ្នាំ ២០១៦ ដល់ថ្ងៃទី ១៨ ខែ កញ្ញា ឆ្នាំ ២០១៦ តាមបញ្ញត្តិមាត្រា ៤០ កថាខណ្ឌ៣ និង កថាខណ្ឌ ៥ ចំណុច១ និង មាត្រា ៣២ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន និង មាត្រា ៤០៤ និង មាត្រា ៤០៦ នៃក្រមព្រហ្មទណ្ឌ ។

២២- ក.ឈ្មោះ [redacted] ប៊ីហៀង ,ឈ្មោះ [redacted] ហេង និង ឈ្មោះ [redacted] សារី បានធ្វើសំណូមពរចុងក្រោយមកសាលាឧទ្ធរណ៍ ដោយសុំលើកលែងចោទប្រកាន់ និង ដោះលែងខ្លួនឲ្យមានសេរីភាពឡើងវិញ សំណូមពរនេះ ក្រុមប្រឹក្សានឹងលើកយកមកពិចារណា សម្រេចតាមការយល់ឃើញខាងលើ ។

ខ.ជនជាប់ចោទឈ្មោះ [redacted] សារ៉ែន បានធ្វើសំណូមពរចុងក្រោយ សុំឲ្យសាលាឧទ្ធរណ៍ជួយសម្រាលទោសឲ្យខ្លួនផង សំណូមពរនេះក្រុមប្រឹក្សាមិនលើកយកមកពិចារណាសម្រេចឡើយ ដោយហេតុថា ជនជាប់ចោទឈ្មោះ [redacted] សារ៉ែន បានទទួលបញ្ជាពីឈ្មោះ ពេន នាង ច្រើនលើក ដែលជាស្ថានទម្ងន់ទោស ។

គ.ជនជាប់ចោទឈ្មោះ [redacted] នាង ហៅ [redacted] វណ្ណដា បានធ្វើសំណូមពរចុងក្រោយមកសាលាឧទ្ធរណ៍ ជួយសម្រាលទោសឲ្យខ្លួនផង សំណូមពរនេះក្រុមប្រឹក្សាសាលាឧទ្ធរណ៍មិនលើកយកមកពិចារណាសម្រេចឡើយ ដោយហេតុថា ជនជាប់ចោទបានជាប់ចោទពីរបទល្មើស ហើយបទល្មើសគ្រឿងញៀនដែលបានចោទប្រកាន់ គឺជនជាប់ចោទបានប្រព្រឹត្តច្រើនដង និង បទល្មើសសម្អាតប្រាក់មានទណ្ឌកម្មកំរិតពី៥ឆ្នាំទៅ១០ឆ្នាំ ដូចនេះឃើញថា ការសម្រេចទណ្ឌកម្មលើជនជាប់ចោទកំណត់៨ឆ្នាំមានលក្ខណៈសមរម្យហើយ ។

២៣- សាលក្រមព្រហ្មទណ្ឌលេខ: ០៧"ឆ" ចុះថ្ងៃទី ២៦ ខែ ០១ ឆ្នាំ ២០១៨ របស់សាលាដំបូងខេត្ត បន្ទាយមានជ័យ សម្រេចមានលក្ខណៈត្រឹមត្រូវហើយ លើកលែងតែចំណុចមួយចំនួនដែលបានយល់ឃើញខាងលើ ត្រូវបដិសេធចោល និង សម្រេចឲ្យជនជាប់ចោទទាំងនោះ រួចខ្លួនពីបទចោទប្រកាន់តាមច្បាប់តទៅ ។

**ហេតុដូច្នេះ**

**វិនិច្ឆ័យសេចក្តី**

១- ក.ទទួលបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី ១៦ ខែ ៣ ឆ្នាំ ២០១៨ របស់ជនជាប់ចោទឈ្មោះ [redacted] នាង ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយផ្ទុយនឹងគតិច្បាប់។

ខ.ទទួលបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី ៣០ ខែ ០១ ឆ្នាំ ២០១៨ របស់ជនជាប់ចោទឈ្មោះ [redacted] សារ៉ែន ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ ។



Scanned with CamScanner

គ.ទទួលបណ្ដឹងឧទ្ធរណ៍ចុះថ្ងៃទី ៣០ ខែ ០១ ឆ្នាំ ២០១៨ របស់ជនជាប់ចោទឈ្មោះ [redacted] មន្នី ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់។

ឃ.ទទួលបណ្ដឹងឧទ្ធរណ៍ចុះថ្ងៃទី ៣០ ខែ ០១ ឆ្នាំ ២០១៨ របស់ជនជាប់ចោទឈ្មោះ [redacted] សីហា ទុកជាត្រឹមត្រូវតាមទម្រង់ និង គតិច្បាប់។

ង.ទទួលបណ្ដឹងឧទ្ធរណ៍ចុះថ្ងៃទី ៣០ ខែ ០១ ឆ្នាំ ២០១៨ របស់ជនជាប់ចោទឈ្មោះ [redacted] លីហៀង ទុកជាត្រឹមត្រូវតាមទម្រង់ និង គតិច្បាប់។

ច.ទទួលបណ្ដឹងឧទ្ធរណ៍ចុះថ្ងៃទី ៣០ ខែ ០១ ឆ្នាំ ២០១៨ របស់ជនជាប់ចោទឈ្មោះ [redacted] ហេង ទុកជាត្រឹមត្រូវតាមទម្រង់ និង គតិច្បាប់។

ឆ.ទទួលបណ្ដឹងឧទ្ធរណ៍ចុះថ្ងៃទី ៣០ ខែ ០១ ឆ្នាំ ២០១៨ របស់ជនជាប់ចោទឈ្មោះ [redacted] សាវី ទុកជាត្រឹមត្រូវតាមទម្រង់ និង គតិច្បាប់។

២- តម្កល់សាលក្រមព្រហ្មទណ្ឌលេខ: ០៧"ឆ" ចុះថ្ងៃទី ២៦ ខែ ០១ ឆ្នាំ ២០១៨ របស់សាលាដំបូងខេត្ត បន្ទាយមានជ័យ ទុកជាបានការ លើកលែងតែចំណុចមួយចំនួនដូចខាងក្រោម៖

ក.ចំណុចទី១ "ង,ច,ឆ និង ញ" ត្រូវបដិសេធចោល និង សម្រេចឲ្យឈ្មោះ [redacted] លីហៀង ឈ្មោះ [redacted] សាវី និង ឈ្មោះ [redacted] ហេង រួចខ្លួនពីបទចោទប្រកាន់គឺបទ: ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន និង បទ: សម្អាតប្រាក់ ប្រព្រឹត្តនៅចំណុចពន្ធនាគារខេត្ត បន្ទាយមានជ័យ និង ចំណុចបន្ទប់ជួលស្ថិតនៅភូមិ ទឹកថ្លា សង្កាត់ ទឹកថ្លា ក្រុង សិរីសោភ័ណ ខេត្ត បន្ទាយមានជ័យ កាលពីអំឡុងឆ្នាំ ២០១៦ ដល់ថ្ងៃទី ១៨ ខែ ៩ ឆ្នាំ ២០១៦ បទល្មើសព្រហ្មទណ្ឌដែលមានចែង និង ផ្ដន្ទាទោសតាមបញ្ញត្តិមាត្រា ៤០ កថាខណ្ឌ៣ និង កថាខណ្ឌ៥ ចំណុច១ នៃច្បាប់ស្ដីពីការត្រួតពិនិត្យគ្រឿងញៀន និង មាត្រា ៤០៤ និង មាត្រា ៤០៦ នៃក្រមព្រទណ្ឌ និងឈ្មោះ [redacted] សីហា រួចខ្លួនពីបទចោទប្រកាន់គឺបទ: សមគំនិតជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅចំណុចពន្ធនាគារខេត្ត បន្ទាយមានជ័យ និង ចំណុចបន្ទប់ជួលស្ថិតនៅភូមិ ទឹកថ្លា សង្កាត់ ទឹកថ្លា ក្រុង សិរីសោភ័ណ ខេត្ត បន្ទាយមាន ជ័យ កាលពីអំឡុងឆ្នាំ ២០១៦ ដល់ថ្ងៃទី ១៨ ខែ ៩ ឆ្នាំ ២០១៦ បទល្មើសដែលមានចែង និង ផ្ដន្ទាទោសតាមបញ្ញត្តិមាត្រា ៤០ កថាខណ្ឌ៣ និង កថាខណ្ឌ៥ ចំណុច១ នៃច្បាប់ស្ដីពីការត្រួតពិនិត្យគ្រឿងញៀន និង មាត្រា ២៩ នៃក្រមព្រហ្មទណ្ឌ ។

ខ.ចំណុចទី១ "ឃ" ស្ដីពីការផ្ដន្ទាទោសលើជនជាប់ចោទឈ្មោះ [redacted] មន្នី ដាក់ពន្ធនាគារកំណត់៥ឆ្នាំ ពីបទ: ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន និង បទ: សម្អាតប្រាក់ ត្រូវសម្រេចបដិសេធចោល នូវបទចោទប្រកាន់ គឺបទ: ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន និង សម្រេចឲ្យជនជាប់ចោទឈ្មោះ [redacted] មន្នី រួចខ្លួនពីបទចោទប្រកាន់ពីបទ: ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅចំណុចពន្ធនាគារខេត្ត បន្ទាយមានជ័យ និង ចំណុចបន្ទប់ជួលស្ថិតនៅភូមិ ទឹកថ្លា សង្កាត់ ទឹកថ្លា ក្រុង សិរីសោភ័ណ ខេត្ត បន្ទាយមានជ័យ កាលពីអំឡុងឆ្នាំ ២០១៦ ដល់ថ្ងៃទី ១៨ ខែ កញ្ញា ឆ្នាំ ២០១៦ បទល្មើសដែលមានចែង និង ផ្ដន្ទាទោសតាមបញ្ញត្តិមាត្រា ៤០ កថាខណ្ឌ៣ និង កថាខណ្ឌ ៥ ចំណុច១នៃច្បាប់ស្ដីពីការត្រួតពិនិត្យគ្រឿងញៀន ។



Scanned with CamScanner

គ.ចំណុចទី១ "ជ" ស្តីពីការផ្តន្ទាទោសលើជនជាប់ចោទឈ្មោះ [redacted] សាវ៉ែន ដាក់ពន្ធនាគារកំណត់០៥ឆ្នាំ ពីបទៈ ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន និង បទៈ សម្អាតប្រាក់ ត្រូវសម្រេចបដិសេធចោលនូវបទចោទប្រកាន់គឺបទៈ សម្អាតប្រាក់ និង សម្រេចឲ្យជនជាប់ចោទឈ្មោះ [redacted] សាវ៉ែន រួចខ្លួនពីបទចោទប្រកាន់ ពីបទៈ សម្អាតប្រាក់ ប្រព្រឹត្តនៅចំណុចពន្ធនាគារខេត្ត បន្ទាយមានជ័យ និង ចំណុចបន្ទប់ជួលស្ថិតនៅភូមិ ទឹកថ្លា សង្កាត់ ទឹកថ្លា ក្រុងសិរីសោភ័ណ ខេត្ត បន្ទាយមានជ័យ កាលពីអំឡុងឆ្នាំ ២០១៦ ដល់ថ្ងៃទី ១៨ ខែ កញ្ញា ឆ្នាំ ២០១៦ បទល្មើសមានថែង និង ផ្តន្ទាទោសតាមមាត្រា ៤០៤, មាត្រា ៤០៦ នៃក្រមព្រហ្មទណ្ឌ ។

៣- បង្គាប់ឲ្យដោះលែងឈ្មោះ [redacted] ហេង ឈ្មោះ [redacted] លីហៀង និង ឈ្មោះ [redacted] សាវី ដែលជាប់ចោទពីបទៈ ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន និង បទៈ សម្អាតប្រាក់ ប្រព្រឹត្តនៅ ចំណុចពន្ធនាគារខេត្ត បន្ទាយមានជ័យ និង ចំណុចបន្ទប់ជួល ស្ថិតនៅភូមិ ទឹកថ្លា សង្កាត់ ទឹកថ្លា ក្រុង សិរីសោភ័ណ ខេត្ត បន្ទាយមានជ័យ កាលពីអំឡុងឆ្នាំ ២០១៦ ដល់ថ្ងៃទី ១៨ ខែ ៩ ឆ្នាំ ២០១៦ បទល្មើសដែលមានថែង និង ផ្តន្ទាទោសតាមមាត្រា ៤០ កថា ខណ្ឌ៣ និង កថា ខណ្ឌ ៥ ចំណុច១ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន និង តាមមាត្រា ៤០៤ និង អាត្រា ៤០៦ នៃក្រមព្រហ្មទណ្ឌ និង ឈ្មោះ [redacted] សីហា ពីបទៈ សមគំនិតក្នុងអំពើជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅចំណុចពន្ធនាគារខេត្តបន្ទាយមានជ័យ និង ចំណុចបន្ទប់ជួលស្ថិតនៅភូមិ ទឹកថ្លា សង្កាត់ ទឹកថ្លា ក្រុង សិរីសោ ភ័ណ ខេត្ត បន្ទាយមានជ័យ កាលពីអំឡុងឆ្នាំ ២០១៦ ដល់ថ្ងៃទី ១៨ ខែ កញ្ញា ឆ្នាំ ២០១៦ តាបមាត្រា ៤០ កថាខណ្ឌ៣ និង កថាខណ្ឌ ៥ ចំណុច១ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន និង មាត្រា ២៩ នៃក្រមព្រហ្មទណ្ឌ ជាបន្ទាន់ កាលបើឈ្មោះខាងលើមិនត្រូវបានឃុំខ្លួនពីបទល្មើសអ្វីផ្សេងទៀតទេ ។

៤- បន្តការឃុំខ្លួនជាបណ្តោះអាសន្នលើឈ្មោះ [redacted] នាង ឈ្មោះ [redacted] មុន្នី និង ឈ្មោះ [redacted] សាវ៉ែន តាមនីតិវិធីច្បាប់ ។

៥- សាលដីកានេះប្រកាសជាសាធារណៈនៅថ្ងៃទី ១៩ ខែ កញ្ញា ឆ្នាំ ២០១៩ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] នាង ,ឈ្មោះ [redacted] សាវ៉ែន ,ឈ្មោះ [redacted] លីហៀង ឈ្មោះ [redacted] ហេង និង ឈ្មោះ [redacted] សាវី កំបាំងមុខឈ្មោះ [redacted] មុន្នី និង ឈ្មោះ [redacted] សីហា ទុកសិទ្ធិឲ្យប្តឹងទាស់ និង ប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់ ។

| **ក្រឡាបញ្ជី** | **ចៅក្រមប្រឹក្សា** | **ប្រធានក្រុមប្រឹក្សា** |
|---|---|---|
| ហត្ថលេខា [redacted] | ហត្ថលេខា [redacted] | ហត្ថលេខា [redacted] |

ថ្ងៃ ច័ន្ទ ១០រោច ខែភទ្របទ ឆ្នាំ កុរ ឯកស័ក ព.ស ២៥៦៣

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

ភ្នំពេញ ថ្ងៃទី ២៣ ខែ កញ្ញា ឆ្នាំ ២០១៩

**ក្រឡាបញ្ជី**

[redacted]

បានឃើញ

**ប្រធានក្រុមប្រឹក្សា**

[redacted]